

UNDP

Empowered lives.
Resilient nations.

# កម្ពុជា

របាយការណ៍ប្រចាំឆ្នាំ ២០១១

# ទិន្នន័យសំខាន់ៗអំពីកម្ពុជា

| | |
|---|---|
| ប្រជាជន | ១៤,៣លាន[១] |
| អត្រាកំណើនប្រជាជនប្រចាំឆ្នាំ | ១,៣៤%[២] |
| ផលទុនក្នុងស្រុក (GDP) សរុបក្នុងឆ្នាំ ២០១១ | ១២,៩ ពាន់លានដុល្លារអាមេរិក[៣] |
| កំណើន GDP ក្នុងឆ្នាំ ២០១១ | ៧,១% [៤] |
| GDP ក្នុងម្នាក់ៗ ក្នុងឆ្នាំ ២០១១ | ៩០៩ ដុល្លារអាមេរិក[៥] |
| អត្រាភាពក្រីក្រ | ២៦,១%[៦] |
| អាយុកាលនៅពេលកើត (បុរស និងស្ត្រី) | ៦២/៦៨,៣[៧] |
| អត្រាមនុស្សពេញវ័យចេះអក្សរ (បុរស និងស្ត្រីអាយុ ១៥ ឆ្នាំឡើង) | ៨៥%/៧១%[៨] |
| អត្រាមរណភាពកុមារ អាយុក្រោម ៥ ឆ្នាំ (ក្នុងកំណើតរស់ ១០០០, ប៉ាន់ស្មាន ឆ្នាំ២០១០) | ៥៤[៩] |
| កុមារអាយុក្រោម ៥ ឆ្នាំ ដែលចាត់ទុកថាមិនគ្រប់ទម្ងន់ (ប៉ាន់ស្មាន ២០១០) | ២៨%[១០] |
| អត្រាមរណភាពមាតា (ក្នុងកំណើតរស់ ១០០.០០០ ប៉ាន់ស្មាន ២០១០) | ២០៦[១១] |
| ប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យអាយុ ១៥-៤៩ (ប៉ាន់ស្មាន ២០១០) | ០,៦%[១២] |
| ភាគរយនៃអ្នកជនបទដែលមានទឹកស្អាតប្រើប្រាស់ | ៤៦% [១៣] |
| ជនស៊ីវិលរងគ្រោះដោយសារគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ឆ្នាំ ២០១១ | ២១១[១៤] |
| ជំនួយអភិវឌ្ឍន៍ផ្លូវការ (ប៉ាន់ស្មានឆ្នាំ ២០១១) | ១,២ ពាន់លានដុល្លារអាមេរិក[១៥] |

១ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
៣ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.mef.gov.kh
៤ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.mef.gov.kh
៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ www.mef.gov.kh
៦ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ (ឯកសារពិនិត្យពាក់កណ្តាលអាណត្តិ ២០១២)
៧ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
៨ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ទំព័រ ១
៩ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ទំព័រ ១១៤
១០ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ទំព័រ ១៤៩
១១ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ២០១០ ទំព័រ xxi
១២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
១៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣
១៤ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងរងគ្រោះពិការដោយសារមីន (CMAA)
១៥ របាយការណ៍ប្រសិទ្ធភាពអភិវឌ្ឍន៍កម្ពុជា ២០១១

Photo credit:
All pictures© UNDP, UNV, Mlub Baitong

# មាតិកា


**អារម្ភកថា** ........ ២

**ការកាត់បន្ថយភាពក្រីក្រ** ........ ៤

សារៈសំខាន់នៃការអភិវឌ្ឍមូលធនមនុស្ស ........ ៤

ជួយការចិញ្ចឹមជីវិតនៅជនបទឲ្យកាន់តែមាននិរន្តរភាព ........ ៥

តាមដានវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ ........ ៧

កំណត់របៀបវារៈ និងការគ្រប់គ្រងវិស័យសំខាន់ៗប្រកបដោយការទទួលខុសត្រូវ ........ ៧

ការបោសសំអាតគ្រាប់មីនសម្រាប់សហគមន៍ប្រើប្រាស់ ........ ៧

ពង្រឹងភាពជាម្ចាស់ ប្រសិទ្ធភាព និងការសម្របសម្រួលជំនួយ ........ ៩

**អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ** ........ ១០

កសាងអភិបាលកិច្ចមូលដ្ឋានដែលឆ្លើយតបតម្រូវការរបស់ពលរដ្ឋបានកាន់តែប្រសើរជាងមុន ........ ១០

ការចូលរួម និងភាពជា តំណាង ........ ១០

បង្កើតលំហសម្រាប់ការរីកញែកបែបប្រជាធិបតេយ្យ ........ ១១

**បរិស្ថាន ថាមពល និងការប្រែប្រួលអាកាសធាតុ** ........ ១៤

ការអភិរក្ស និងការប្រើប្រាស់ធនធានធម្មជាតិ ........ ១៤

ការប្រែប្រួលអាកាសធាតុ ........ ១៥

ជំរុញការអនុវត្តទំលាប់ល្អៗក្នុងវិស័យកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ ........ ១៥

កម្មវិធីបន្សាំសហគមន៍ ........ ១៦

**ជំរុញសមភាពយេនឌ័រ** ........ ២០

**ធ្វើការរួមគ្នា** ........ ២២

**កិច្ចសហប្រតិបត្តិការត្បូង-ត្បូង** ........ ២៤

**ចំណាយរបស់កម្មវិធី** ........ ២៦


គោលដៅ
អភិវឌ្ឍន៍
សហស្សវត្សរ៍
កម្ពុជា



# អារម្ភកថា

នៅខែមិនា ឆ្នាំ២០១១ UNDP ប្រចាំកម្ពុជាបានសម្ភោធកម្មវិធីការងារអភិវឌ្ឍន៍របស់ខ្លួនសំរាប់ឆ្នាំ ២០១១-២០១៥ ដែលផ្តោតលើការបង្កើនល្បឿនវឌ្ឍនភាពក្នុងការសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។ កម្មវិធីការងារនេះត្រូវបានតាក់តែងឡើងនៅជុំវិញបញ្ហាស្នូលបី គឺ កំណើនដោយមានការគិតគូរដល់គ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ ការចូលរួមរបស់ពលរដ្ឋក្នុងកិច្ចអភិវឌ្ឍន៍ និងការធ្វើឲ្យមានចីរភាពបរិស្ថាន។

ក្នុងកិច្ចខិតខំរបស់យើងដើម្បីរួមចំណែកដល់លទ្ធផលនៃកិច្ចអភិវឌ្ឍន៍ យើងទទួលស្គាល់ថា UNDP ត្រូវតែរួមកំលាំងនិងធនធានជាមួយដៃគូទាំងអស់។ ជាសមាជិកម្នាក់ក្នុងសហគមន៍អភិវឌ្ឍន៍ យើងមានសេចក្តីសោមនស្សរីករាយជាមួយនឹងទំនាក់ទំនងរឹងមាំដែលយើងមានជាមួយដៃគូទាំងអស់។

វិស័យសំខាន់ៗរបស់យើងមានផ្នែកកាត់បន្ថយភាពក្រីក្រ អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ បរិស្ថាន និងថាមពល។ ការលើកស្ទួយសមភាពយេនឌ័រជាការងារអន្តរវិស័យដែលផ្តោតទៅលើសកម្មទាំងឡាយសំដៅជួយស្ត្រីកម្ពុជាឲ្យមានស្ថានភាពសង្គម-នយោបាយ និងភាពអង់អាចផ្នែកសេដ្ឋកិច្ចកាន់តែប្រសើរជាងមុន។ ក្នុងឆ្នាំ ២០១១ យើងធ្វើការជាមួយរដ្ឋាភិបាលដោយផ្តោតលើការរកវិធីកសាងមូលធនមនុស្ស គាំពារដល់វិស័យកសិកម្ម និងការអភិវឌ្ឍឧស្សាហកម្ម។ កិច្ចខិតខំរបស់យើងក្នុងផ្នែកបោសសំអាតគ្រាប់មីនបានរំដោះដីឲ្យសហគមន៍យកទៅធ្វើកសិកម្ម និងកសាងហេដ្ឋារចនាសម្ព័ន្ធ។ ជាមួយគ្នានេះដែរ យើងក៏បានធ្វើការងារជួយកែលំអជីវភាពប្រជាជនក្នុងទីជនបទតាមរយៈគំរោងបង្កើតចំណូលប្រកបដោយចីរភាព។



លោក សេត ឃឿន អាយុ ៤៨ ឆ្នាំ កំពុងពិនិត្យមើលផ្លែននោង ក្នុងសួនបន្លែនៅមុខផ្ទះរបស់គាត់ក្នុងខេត្តសៀមរាប។

កិច្ចគាំពារដល់កំណែទម្រង់វិមជ្ឈការ និងការបង្ហិតកិច្ចដឹកនាំតាមបែបប្រជាធិបតេយ្យឲ្យកាន់តែជិតប្រជាពលរដ្ឋ ត្រូវបានធ្វើឡើងតាមរយៈគំរោងកិច្ចសហប្រតិបត្តិការ អន្តរ-ឃុំ។ រីឯរបាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជា ២០១១ ដែលត្រូវបានផលិតឡើងរួមគ្នាជាមួយរាជរដ្ឋាភិបាល ធ្វើការសង្កត់ធ្ងន់ទៅលើសារៈសំខាន់ នៃការប្រើប្រាស់អភិក្រមបែបសមាហរណកម្ម ក្នុងការលៃលកជាមួយបញ្ហាការប្រែប្រួលអាកាសធាតុ។

ឥទ្ធិពលនៃការប្រែប្រួល អាកាសធាតុកំពុងកើតមាននៅទូទាំងប្រទេស ហើយដោយសារមូលហេតុនេះ ការងាររបស់យើងបានផ្តោតលើវិស័យដែលចាំបាច់បំផុត រួមមានវិស័យធនធានទឹក កសិកម្ម ព្រៃឈើ និងនេសាទ ដោយផ្សារភ្ជាប់ការអភិរក្សជាមួយវិធីប្រកបច្នៃប្រឌិត និងចីរភាព ដើម្បីកែលំអជីភាពពលរដ្ឋនៅជនបទ។

ការលើកយកបញ្ហាយេនឌ័រទៅដាក់ក្នុងរបៀបវារៈកិច្ចពិភាក្សាកំរិតខ្ពស់ គឺជាចំណុចយកចិត្តទុកដាក់ពិសេសនៅឆ្នាំ ២០១១។ កិច្ចផ្តួចផ្តើមគំនិតចំនួនប្រាំផ្នែកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ត្រូវបានបន្ថែមការយល់ដឹងអំពីយេនឌ័រ ដើម្បីជាប្រយោជន៍ដល់ស្ត្រី។ ផែនការសកម្មភាពយេនឌ័រត្រូវបានបង្កើតសំដៅធ្វើឲ្យកាន់តែប្រសើរនូវការអប់រំសិក្សា និងសុខភាពស្ត្រី បង្កើនការរកចំណូល និងភាពងង់អាចរបស់ពួកគេឈានទៅកាន់តួនាទីដឹកនាំ។

តទៅមុខ យើងនឹងបន្តការងារដោយឈរលើមូលដ្ឋានរឹងមាំ ដែលយើងបានកសាងរួចមកហើយនេះ និងខិតខំសំរេចឲ្យបានថែមទៀតនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលតាមរយៈនេះ ជនកម្ពុជាគ្រប់រូប បុរស ស្ត្រី កុមារ អាចទទួលបាននូវផលប្រយោជន៍ពីសង្គមប្រជាធិបតេយ្យ សេដ្ឋកិច្ចរឹងមាំ មានការគិតគូរដល់ទាំងអស់គ្នា និងបរិស្ថានមានចីរភាព និងភាពស្វិតស្វាញទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។



អ្នកស្រី មុត ផល្លា និងចៅស្រីរបស់គាត់ កំពុងដាំត្រប់ក្នុងសួនបន្លែគាត់នៅ ខេត្តសៀមរាប។ សួនបន្លែនេះត្រូវបានបំពាក់ដោយប្រព័ន្ធស្រោចស្រពដែលត្រូវបានឧបត្ថម្ភពីគម្រោងមួយរបស់ UNDP។

# ការកាត់បន្ថយភាពក្រីក្រ

## សារៈសំខាន់នៃការអភិវឌ្ឍមូលធនមនុស្ស

*សមិទ្ធផលកំណើនគួរឲ្យកត់សំគាល់របស់កម្ពុជានឹងមានចីរភាព ប្រសិនបើកម្ពុជាពង្រីកការយកចិត្តទុកដាក់បន្ថែមលើវិស័យមួយចំនួនដែលជាទីសង្ឃឹម និងផ្តោតលើការអភិវឌ្ឍធនធានធម្មជាតិដោយចីរភាព។ ដើម្បីក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលកម្រិតមធ្យម ទន្ទឹមនឹងការធ្វើវឌ្ឍនភាពឆ្ពោះទៅកាត់បន្ថយភាពក្រីក្រ កម្ពុជាត្រូវធានាថា យុទ្ធសាស្ត្រកំណើន និងអន្តរាគមន៍សម្រាប់រយៈពេលមធ្យមរបស់ខ្លួនមានលក្ខណៈពេញលេញ មាននិរន្តរភាពជាងមុន និងជាមួយស្ថាប័នដែលរឹងមាំជាងមុន។*

កម្ពុជាបានស្តារសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅឆ្នាំ ២០១១ ដោយមានកំណើន GDP តាមអត្រាប៉ាន់ស្មាន ៧,១%។ តាមអត្រានិទស្សន៍នេះ កម្ពុជានឹងចាប់ផ្តើមក្លាយជាប្រទេសមានប្រាក់ចំណូលកម្រិតមធ្យមទាបនៅក្នុងរយៈពេលប្រាំឆ្នាំខាងមុខ។ អាស្រ័យហេតុនេះ រដ្ឋាភិបាលបានបង្កើនកិច្ចប្រឹងប្រែងដើម្បីពង្រីកមូលដ្ឋាននៃកំណើន ដោយផ្តោតលើកសិកម្ម ឧស្សាហកម្ម និងមូលធនមនុស្ស។ កម្ពុជាទទួលស្គាល់ថា ការអភិវឌ្ឍមូលធនមនុស្សមានសារៈសំខាន់ជាស្នូលនៃការកសាងកម្លាំងពលកម្មដែលរឹងមាំប្រកបដោយគុណភាព និងមានជំនាញដែលកម្ពុជាត្រូវការជាចាំបាច់ដើម្បីជម្រុញចក្ខុវិស័យ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍនេះ។

សារៈសំខាន់បានផ្តោតលើការអភិវឌ្ឍជំនាញ ដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍក្នុងដំណាក់កាលដំបូងរបស់កុមារ អាហារូបត្ថម្ភ សុខភាព ការទទួលបានការសិក្សាអប់រំជាមូលដ្ឋានស្របគ្នានឹងការបង្កើនការអប់រំជាន់ខ្ពស់ និងបណ្តុះបណ្តាលវិជ្ជាជីវៈបច្ចេកទេស។ កិច្ចគាំពារសង្គមក៏មានសារៈសំខាន់ដែរក្នុងទិដ្ឋភាពនេះ។

ចំណុចលេចធ្លោ គឺភាពចាំបាច់ដើម្បីអភិវឌ្ឍន៍ជំនាញនៅក្នុងវដ្តរបស់វាដែលផ្សារភ្ជាប់ការអភិវឌ្ឍតាំងពីកុមារភាព អាហារូបត្ថម្ភ សុខភាព និងការអប់រំបឋម ជាមួយការកែលំអលើការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការអប់រំជាន់ខ្ពស់ និងការគូសបញ្ជាក់អំពីសារៈសំខាន់នៃកិច្ចគាំពារសង្គម។ របាយការណ៍មូលធនមនុស្សថែងអំពីកម្លាំងពលកម្ម ដែលបំពាក់ដោយមិនត្រឹមតែសមិទ្ធផលខាងការសិក្សាវិទ្យាសាស្ត្រ ប៉ុន្តែចំណេះដឹងបច្ចេកទេស និងជំនាញជាមូលដ្ឋានខាងផ្នែកទំនាក់ទំនងផងដែរ ដូចជាការអនុវត្តការងារជាក្រុមការគ្រប់គ្រងខ្លួនឯង ឬការដោះស្រាយបញ្ហា គឺជាអ្វីដែលកម្ពុជាពិតជាត្រូវការ ដើម្បីដាក់ប្រទេសនេះទៅក្នុងលំនាំផ្លូវមួយនៃការលូតលាស់ដែលមាននិរន្តរភាព និងប្រកបដោយភាពធន់ទ្រាំ។ របាយការណ៍នេះ ក៏គូសបញ្ជាក់ផងដែរអំពីសារៈសំខាន់នៃការជម្រុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវិស្វកម្ម នៅក្នុងការសិក្សាជាន់ខ្ពស់។



*អឿន សុហ៊ិត អាយុ ២៨ ឆ្នាំ កំពុងជួសជុលទូរទស្សន៍ក្នុងរោងជាងនៅមុខផ្ទះរបស់ គាត់ក្នុងខេត្តតាកែវ។ កម្ពុជាត្រូវការបណ្តុះបណ្តាលនិងពង្រឹងថែមទៀតនូវមូលធនមនុស្សដែលមានចំណេះដឹង និងជំនាញសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព។*

វេទិកាសេដ្ឋកិច្ចកម្ពុជាលើកទី៤ ស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍឧស្សាហកម្ម ត្រូវបានធ្វើឡើងនៅខែកុម្ភៈ ២០១១។ វេទិកានោះបានដាក់ចេញនូវរបៀបវារៈនយោបាយសេដ្ឋកិច្ច ដោយផ្តោតលើសារៈសំខាន់នៃការវិនិយោគលើការអប់រំ និងបណ្តុះបណ្តាលជំនាញ។ បន្ទាប់មកទៀត ការសិក្សាមួយ ដែលមានការគាំទ្រដោយ UNDPស្តីពីមូលធនមនុស្សសំរាប់ធ្វើពិពិធកម្មសេដ្ឋកិច្ច បានជួយគូសទិសដៅ និងជំហានឆ្ពោះទៅធ្វើផែនទីបង្ហាញផ្លូវសំរាប់ការអភិវឌ្ឍមូលធនមនុស្សផងដែរ។

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) បានរៀបចំឡើងវិញនូវដេប៉ាតឺម៉ង់ធនធានភូគព្ភសាស្ត្រ និងវិស្វកម្មបច្ចេកទេសភូគព្ភសាស្ត្រ ក្រោយពីបានបិទទ្វារនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ វិទ្យាស្ថាននេះមានគោលដៅដើរតួនាទីសំខាន់មួយ ក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ដោយផ្តល់ឲ្យនិស្សិតនូវជំនាញបច្ចេកទេសទំនើប និងចំណេះធ្វើខាងវិទ្យាសាស្ត្រភូគព្ភសាស្ត្រ និងវិស្វកម្មបច្ចេកទេសភូគព្ភសាស្ត្រ និងមុខវិជ្ជាដែលពាក់ព័ន្ធ។

ការអប់រំ គឺជាផ្នែកគន្លឹះមួយនៃការកសាងវិស័យអាជីវកម្មរ៉ែ និងប្រេងកាត និងឧស្ម័ន ប្រកបដោយការទទួលខុសត្រូវនៅកម្ពុជា។ តាមរយៈចំណេះដឹង ជនកម្ពុជានឹងមានចំណេះដឹងក្នុងការចាប់យកជម្រើសត្រឹមត្រូវសម្រាប់វិស័យឧស្សាហកម្មនិស្សារណកម្ម ដែលមានលក្ខណៈឌីណាមិក និងប្រកបដោយការទទួលខុសត្រូវទាំងខាងសង្គម និងបរិស្ថាន។

## ជួយការចិញ្ចឹមជីវិតនៅជនបទឲ្យកាន់តែមាននិរន្តរភាព

នៅឆ្នាំ២០១១ពលរដ្ឋកម្ពុជារាប់ពាន់នាក់នៅទីជនបទបានទទួលផលប្រយោជន៍ពីបណ្តាគំរោងនានា ដែលជួយកែលំអការចិញ្ចឹមជីវិតរបស់ពួកគេឲ្យប្រសើរឡើង។ កម្មវិធីបន្សាំនៅតាមសហគមន៍ (Cambodia Community-Based Adaptation Programme) បានផ្តល់មូលនិធិដល់គម្រោងចំនួន ៤៥ ដើម្បីបង្ហាញអំពីបច្ចេកទេសធន់ទ្រាំទៅនឹងអាកាសធាតុ ទាំងនៅកម្រិតសហគមន៍ និងគ្រួសារ។

គម្រោងទាំងនោះ ធ្វើក្នុងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងមូលដ្ឋាន និងអង្គការសហគមន៍នានា សំដៅធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពរបស់អ្នកស្រុកក្នុងការស្មានទុក និងបន្ថយស្ថានភាពអាក្រក់នៃការប្រែប្រួលអាកាសធាតុ។ វាបានជួយគ្រួសារជនបទនូវពូជស្រូវដែលមានភាពធន់នឹងភាពរាំងស្ងួត និងទឹកជំនន់ និងបានណែនាំពួកគេអំពីបច្ចេកទេសក្នុងការគ្រប់គ្រងធនធានទឹកសម្រាប់ធ្វើការដាំដុះ។ ថែមពីលើនេះ គម្រោងទាំងនោះបានលើកទឹកចិត្តកសិករឲ្យបង្កើនចម្រុះភាពក្នុងការដាំដុះរបស់ខ្លួន ដូចជា ការធ្វើស្រូវប្រពលវប្បកម្ម ការដាំបន្លែ ការចិញ្ចឹមសត្វ ដែលទាំងអស់នេះសុទ្ធតែមានប្រយោជន៍ជួយបង្កើនសន្តិសុខស្បៀងរបស់ពួកគេចំពោះមុខឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ។

ឆ្នាំ ២០១១ ជាឆ្នាំចុងក្រោយនៃកម្មវិធីរួមគ្នារបស់ អ.ស.ប ដែលក្នុងនោះ UNDP បានសម្រេចក្នុងការគាំទ្រដល់ពលរដ្ឋជាជនជាតិដើម ក្នុងការធ្វើពាណិជ្ជកម្មផលិតផលវប្បធម៌មួយចំនួនរបស់ពួកគេ។ កិច្ចការនេះបាននាំឲ្យមានកំណើនផលចំណូលប្រចាំខែសម្រាប់សហគមន៍ បានពង្រឹងផលិតកម្ម និងសមត្ថភាពក្នុងការលក់ និងការបង្កើតទីផ្សារថ្មីៗ ដែលផ្សារភ្ជាប់រវាងសហគមន៍ និងអ្នកទិញនៅថ្នាក់ជាតិ។

ផលិតផលវប្បធម៌របស់ជនជាតិដើម ត្រូវបានដាក់តាំងបង្ហាញតាមរយៈអ្នកច្នៃប្រឌិតជាជនជាតិដើមនៅក្នុងការប្រកួតប្រជែង និងពិព័រណ៍ប្រចាំឆ្នាំ។ ពិព័រណ៍ដែលមានរយៈពេលប្រាំសប្តាហ៍ ត្រូវបានធ្វើឡើងនៅក្នុងសារមន្ទីរជាតិកម្ពុជា ក្រោមកិច្ចសហការជិតស្និទ្ធជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងពាណិជ្ជកម្ម។ នេះ គឺជាព្រឹត្តិការណ៍លំដាប់ខ្ពស់មួយដែលមានការបញ្ជាទិញផលិតផលរបស់ជនជាតិដើមតាមរយៈសមាគមសិប្បករកម្ពុជា ដើម្បីសាកល្បងទីផ្សារនៅក្នុងប្រទេសអាល្លឺម៉ង់។

ការថែរក្សាវប្បធម៌ជនជាតិដើម និងការពង្រឹងភាពអង់អាចខាងសេដ្ឋកិច្ចនៅក្នុងមូលដ្ឋាន ត្រូវបានពិភាក្សានៅថ្នាក់ជាតិជាមួយរដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ អង្គការសង្គមស៊ីវិល និងសហគមន៍ជនជាតិដើម។

*"នេះជាលើកដំបូងដែលយើងប៉ុនប៉ងដោះស្រាយបញ្ហាមូលធនមនុស្ស ដោយផ្អែកតាមទស្សនវិស័យនៃការអភិវឌ្ឍឧស្សាហកម្ម។ នេះជាជំហានថ្មីមួយ ជាការចាប់ផ្តើមដ៏ល្អមួយ ដែលបើទោះជាមានការប្រឈមនៅខាងមុខក៏ដោយ នឹងអនុញ្ញាតឲ្យរដ្ឋាភិបាលកំណត់ចំណុចដៅសម្រាប់អន្តរាគមន៍គោលនយោបាយបានប្រសើរជាងមុន។ របាយការណ៍មូលធនមនុស្សមិនត្រឹមតែចង្អុលបង្ហាញអំពីចំណុចខ្វះខាតប៉ុណ្ណោះទេ ប៉ុន្តែក៏ផ្តល់នូវការណែនាំ និងផែនទីបង្ហាញផ្លូវដើម្បីដោះស្រាយផងដែរ។"*

*ឯកឧត្តម រស់ សីលវ៉ា*
*អគ្គលេខាធិការរងនៃ*
*ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ*

## លើកស្ទួយសិប្បកម្មតម្បាញជនជាតិភាគតិច

តម្បាញ គឺជាផ្នែកមួយនៃអត្តសញ្ញាណវប្បធម៌របស់ភូមិខ្នាច នៅក្នុងខេត្តរតនៈគីរី ភាគឦសាននៃប្រទេសកម្ពុជា ដែលសិល្បៈនេះ ត្រូវបានបញ្ជូនបន្តគ្នាពីជំនាន់មួយទៅជំនាន់មួយទៀត។ ប៉ុន្តែក្នុងពេលថ្មីៗនេះ អ្នកភូមិបានចាប់ផ្តើមរៀនសូត្រអំពីគោលគំនិតថ្មីអំពីសហគ្រិន ដែលពួកគេមើលឃើញការត្រួតពិនិត្យគុណភាព និងទំនាក់ទំនងទីផ្សារ គឺជាគន្លឹះនៃការលក់ផលិតផលរបស់ពួកគេ។

ផ្កាញ់ ព្រលាវ នៃក្រុមជនជាតិដើមភាគតិចគ្រឿន គឺជាអ្នកភូមិម្នាក់ក្នុងចំណោមអ្នកភូមិ ១៩៥ នាក់ នៅក្នុងភូមិចំនួន ១០ ដែល UNDP ជួយ ស្វែងរកវិធីប្រសើរជាងមុន ដើម្បីលក់ផលិតផលសិប្បកម្មរបស់ពួកគេ ដើម្បីបង្កើនប្រាក់ចំណូល។



លោកស្រី គុល ប៉ុល ជនជាតិដើមភាគតិចគ្រឹង កំពុងត្បាញកន្សែងជនជាតិមួយដែលជា ផលិតផលសិប្បកម្មក្នុងការរកចំណូលសម្រាប់គ្រួសាររបស់គាត់នៅខេត្តរតនគីរី។

អន្តរាគមន៍របស់ UNDP គឺជាផ្នែកមួយនៃកម្មវិធីគាំទ្រឧស្សាហកម្មច្នៃប្រឌិត ដែលជាកិច្ចផ្តួចផ្តើមពហុទីភ្នាក់ងារដែលមាន UNDP, UNESCO, អង្គការពលកម្មអន្តរជាតិ និងអង្គការស្បៀង និងកសិកម្ម។ ក្រោមកិច្ចសហការជាមួយមូលនិធិសមិទ្ធផលគោលដៅសហស្សវត្សរ៍នៃ អ.ស.ប និងប្រទេសអេស្ប៉ាញ (MDG-F), កម្មវិធីនេះធ្វើការ ដើម្បីថែរក្សា និងលើកកំពស់បេតិកភណ្ឌវប្បធម៌កម្ពុជា និងការចិញ្ចឹមជីវិតរបស់ជនជាតិដើម និងសិប្បករខ្មែរចំនួនច្រើនជាង ៨០០នាក់។ កម្មវិធីនេះធ្វើការនៅក្នុងខេត្តចំនួនបួន គឺកំពង់ធំ ព្រះវិហារ មណ្ឌលគិរី និងរតនៈគិរី។

នៅរតនៈគីរី អង្គការអភិវឌ្ឍន៍អនុផលព្រៃឈើកម្ពុជា (CANDO), បានជួយអ្នកភូមិជនជាតិដើមក្នុងការស្វែងរកទីផ្សារសម្រាប់វត្ថុសិប្បកម្មរបស់ពួកគេ។ អង្គការមិនមែនរដ្ឋាភិបាល ក៏បានបណ្តុះបណ្តាលអ្នកភូមិអំពីការកសាងផែនការជំនួញ ការគ្រប់គ្រងហិរញ្ញវត្ថុ ការកំណត់ថ្លៃ ការត្រួតពិនិត្យគុណភាព និងទំនាក់ទំនងទីផ្សារ ពោល គឺចំណេះដឹងដែលអាចឲ្យពួកគេប្រើប្រាស់ទីផ្សារបានធំទូលាយ។

ហេង សុជាតិ មកពីអង្គការ CANDO បានពោលថា "កាលពីមុន ពួកគេមិនយល់ថា តើទីផ្សារដំណើរការបែបណាឡើយ "។

"ប៉ុន្តែតាមរយៈការបណ្តុះបណ្តាល បច្ចុប្បន្នពួកគេយល់បានល្អជាងមុនអំពីទំនាក់ទំនងរវាងការទិញ និងលក់។ ពួកគេដឹងអំពីរបៀបគិតបញ្ចូលថ្លៃវត្ថុធាតុដើម ពលកម្ម និងឧបករណ៍ផលិត និងថ្លៃចំណាយផ្សេងទៀត និងរបៀបកំណត់ថ្លៃលក់ផលិតផលរបស់ពួកគេ។"

## តាមដានវឌ្ឍនភាពនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍

នៅក្នុងប៉ុន្មានឆ្នាំកន្លងទៅនេះ កម្ពុជាសម្រេចបាននៅកម្រិតថ្នាក់ជាតិនូវវឌ្ឍនភាពជាដុំកំភួនក្នុងការកាត់បន្ថយភាពក្រីក្រ អមដោយវឌ្ឍភាពគួរឲ្យកត់សំគាល់ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍មួយចំនួនផង។ ទោះជាយ៉ាងណាក៏ដោយវឌ្ឍនភាពទាំងនោះមានលក្ខណៈខុសៗគ្នាយ៉ាងច្រើនរវាងតំបន់ក្នុងប្រទេស។

ក្នុងគោលបំណងកំណត់ឧបសគ្គរាំងស្ទះ ដល់ការឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ដែលនឹងតម្រូវឲ្យមានអន្តរាគមន៍ជាចាំបាច់នោះ តារាងពិន្ទុ CMDG ត្រូវបានធ្វើឡើងដោយផ្អែកលើកម្រងទិន្នន័យឃុំ។ ទិន្នន័យនេះជាសំណុំព័ត៌មានស្ថិតិដ៏មានតម្លៃស្តីពីនិន្នាការប្រជាសាស្ត្រ និងសង្គមសេដ្ឋកិច្ចនៅថ្នាក់ក្រោមជាតិ។ នៅឆ្នាំ ២០១១ កម្រងសំណួរទិន្នន័យឃុំ ត្រូវបានកែលំអឆ្លងតាមដំណើរការមួយ ដែលមានការចូលរួមមនុស្សជាង ១00 នាក់ មកពីមន្ទីរពាក់ព័ន្ធខេត្ត។ ការពិនិត្យឡើងវិញនេះ បានបញ្ចូលសំណួរថែមទៀតមកពីថ្នាក់ស្រុក។ ដំណើរការនេះ ធ្វើឡើងក្នុងគោលបំណងធ្វើឲ្យកាន់តែប្រសើរនូវភាពគ្រប់ជ្រុងជ្រោយរបស់ទិន្នន័យស្តីពីឧទាហរណ៍ផលិតកម្មកសិកម្ម ភាពខុសគ្នាតាមតំបន់នៃការប្រែប្រួលអាកាសធាតុ ការអប់រំ ភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ការបំពាន និងអំពើហិង្សាក្នុងគ្រួសារ លទ្ធភាពទទួលបានទឹកនិងអនាម័យ និងមរណភាពដោយជំងឺផ្សេងៗ។ ជាលទ្ធផលកម្រងសំណួរថ្មីត្រូវបានបង្កើត និងធ្វើការសាកល្បងមគ្គុទេសក៍សម្រាប់ប្រមូលទិន្នន័យ ត្រូវបានធ្វើបច្ចុប្បន្នភាព ហើយមន្ត្រីផែនការ និងមន្ត្រីខេត្តក្រុងទាំង ២៤ ក៏បានទទួលការហ្វឹកហ្វឺកអំពីការប្រមូលទិន្នន័យដែរ។ កម្រងសំណួរថ្មីនេះបាននាំដល់ការបង្កើតនូវតារាងពិន្ទុ CMDG ថ្មីផងដែរសម្រាប់រដ្ឋាភិបាលមានព័ត៌មានពេញលេញជាងមុនយកទៅធ្វើផែនការ និងការសម្រេចចិត្ត និងពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ផង។

" បន្ទាប់បានឃើញនូវការអនុម័ត និងការចូលជាធរមានជាប្រវត្តិសាស្ត្រនៅក្នុងពេលថ្មីៗនេះនៃអនុសញ្ញាស្តីពីគ្រាប់បែកចង្កោម កិច្ចប្រជុំលើកទី ១១ នេះ ក៏ជាឱកាស ដើម្បីទទួលស្គាល់អំពីអំណាចនៃភាពជាដៃគូរវាងរដ្ឋនានា សង្គមស៊ីវិល និងអង្គការអន្តរជាតិ ក្នុងការជម្រុញកិច្ចការទូតសម្រាប់ការងារមនុស្សធម៌ផងដែរ ដែលជាការទប់ស្កាត់ និងជួយកសាងពិភពលោកមួយ ដែលមានសន្តិភាព និងសន្តិសុខជាងមុនផងដែរ។"

*ហេឡិន ក្លាក ប្រធាន UNDP*

## កំណត់របៀបវារៈ និងការគ្រប់គ្រងវិស័យសំខាន់ៗប្រកបដោយការទទួលខុសត្រូវ

វិស័យឧស្សាហកម្មនិស្សារណកម្ម ត្រូវបានរាជរដ្ឋាភិបាលកំណត់ថាជា វិស័យអាទិភាពសម្រាប់ពិពិធកម្មសេដ្ឋកិច្ច។ នៅឆ្នាំ ២០១១ រដ្ឋាភិបាល បានបង្កើនកម្រិតចំណាប់អារម្មណ៍ និងការត្រៀមខ្លួនដើម្បីធ្វើការលើគោលនយោបាយយុទ្ធសាស្ត្រ និងក្របខ័ណ្ឌសំខាន់ៗ។ វិស័យចំនួនពីរ គឺការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយប្រេងនិងឧស្ម័នជាមួយអាជ្ញាធរប្រេងកាតជាតិកម្ពុជា និងគោលនយោបាយរ៉ែ ជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ការកសាងគោលនយោបាយប្រេងកាត គឺជាទិដ្ឋភាពសំខាន់មួយនៅក្នុងការគ្រប់គ្រងធនធានប្រេងកាតរបស់កម្ពុជា និងជាជំហានសំខាន់ថ្មីមួយទៅមុខនៅក្នុងកិច្ចប្រឹងប្រែង ដើម្បីជួយកម្ពុជាអភិវឌ្ឍន៍វិស័យប្រេងកាត និងឧស្ម័នដែលទើបលេចឡើងថ្មី។

## បោសសំអាតគ្រាប់មីនយកដីជូនសហគមន៍

កម្ពុជាបានធ្វើឲ្យមានការរីកចម្រើនយ៉ាងល្អនៅក្នុងឆ្នាំ ២០១១ លើសកម្មភាពបោសសំអាតគ្រាប់មីនដោយរដ្ឋាភិបាល និងភ្នាក់ងារប្រតិបត្តិបង្កើនកិច្ចប្រឹងប្រែងបោសសំអាតគ្រាប់មីន។

កិច្ចប្រឹងប្រែងជាច្រើនលើការបោសសំអាតគ្រាប់មីន និងការអប់រំអំពីហានិភ័យនៃគ្រាប់មីនបាននាំឲ្យមានការថយចុះជាខ្លាំងនៃករណីរងរបួសនៅក្នុងបណ្តាឆ្នាំកន្លងមកនេះ។ ក្នុងឆ្នាំ ២០១១ កម្ពុជាមានអត្រាទាបបំផុតនៃករណីគ្រោះថ្នាក់ ដោយសារគ្រាប់មីនបង្កប់ក្នុងដី និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ (២១១) នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។

*"បើគ្មានការបង្កើនល្បឿន និង ប្រសិទ្ធភាពនៃវិធីដែលយើង ដោះស្រាយបញ្ហារៀងៗខ្លួន របស់យើងទេនោះ គោលដៅ ចុងក្រោយរបស់យើងនៃការ ធ្វើឲ្យមានពិភពលោកមួយ ដែលគ្មានគ្រាប់មីន នឹងនៅ តែស្ថិតនៅឆ្ងាយពីយើង ដដែល។"*

**នាយករដ្ឋមន្ត្រី ហ៊ុន សែន**

កម្ពុជាបានបង្កើនផលិតភាព និងប្រសិទ្ធភាពនៃកម្មវិធីបោសសំអាតគ្រាប់មីនរបស់ខ្លួន។ នៅក្នុងឆ្នាំ ២០១១ តាមរយៈគម្រោងរបស់ UNDP កម្មវិធីបោសសំអាតដើម្បីលទ្ធផលជំហាន ទី ២ ផ្ទៃដីទំហំ ៨,៩ គីឡូម៉ែត្រក្រឡានៅក្នុងតំបន់ដែលមានគ្រាប់មីនច្រើនជាងគេ និងដែលមានហានិភ័យខ្ពស់ជាងគេ ត្រូវបានរំដោះពីគ្រាប់មីន។ បច្ចុប្បន្ននេះ ការយកចិត្តទុកដាក់បានផ្តោតលើការធ្វើឲ្យប្រាកដថា ដីដែលបានដោះមីនរួច នឹងត្រូវប្រគល់ទៅឲ្យសហគមន៍សម្រាប់ការប្រើប្រាស់ក្នុងផលិតកម្ម។

ការដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំលើកទី ១១ នៃរដ្ឋជាភាគីនៅក្នុងអនុសញ្ញាហាមឃាត់គ្រាប់មីនប្រឆាំងមនុស្សនៅឆ្នាំ២០១១ វាបានបង្ហាញអំពីសមត្ថភាពរបស់រដ្ឋាភិបាលក្នុងតួនាទីនាំមុខលើសកម្មភាពបោសសំអាតគ្រាប់មីន និងក្នុងការបង្ហាញពីបទពិសោធន៍របស់កម្ពុជានៅក្នុង MDG9 ស្តីពីការបោសសំអាតគ្រាប់មីន។ មានប្រសាសន៍នៅក្នុងពិធីបើកសន្និសីទនេះ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី បានអំពាវនាវឲ្យមានកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំជាងមុនក្នុងចំណោមរដ្ឋភាគីទាំងអស់នៅក្នុងអនុសញ្ញានេះ និងអ្នកពាក់ព័ន្ធនានា ដើម្បីធ្វើការជាមួយគ្នា "ឆ្ពោះទៅបុព្វហេតុដ៏ត្រឹមត្រូវរបស់យើង ដើម្បីពិភពលោកមួយដែលគ្មានគ្រាប់មីន "។

ក្រោយកិច្ចប្រជុំនេះ កម្ពុជាបានទទួលការសន្យាផ្តល់ហិរញ្ញវត្ថុសម្រាប់បោសសំអាតគ្រាប់មីន និងប្រើប្រាស់ដីសម្រាប់ការអភិវឌ្ឍ។ ប្រទេសអូទ្រីសបានប្រកាសវិភាគទានចំនួន ៤០០.០០០ អឺរ៉ូ សម្រាប់ការដោះមីន និងជួយជនរងគ្រោះប្រទេសនូវែលហ្សេឡង់ នឹងរួមចំណែកច្រើនជាង ១ លានដុល្លារ នៅក្នុងឆ្នាំ ២០១២ សម្រាប់គម្រោងដោះមីននៅភាគពាយព្យនៃប្រទេស និងប្រទេសអេស្ប៉ាញ បានសន្យាផ្តល់ប្រមាណ ៤០០.០០០ អឺរ៉ូ។

កាលពីឆ្នាំទៅ ជនកម្ពុជានៅជនបទប្រមាណ ៣.៣២៩ គ្រួសារ បានទទួលដីពីការបោសសំអាតគ្រាប់មីនសម្រាប់សង់ផ្ទះ និងប្រើប្រាស់សម្រាប់កសិកម្ម។ គ្រួសារចំនួន ៤១.៩៥១ ផ្សេងទៀត ដែលមានសមាជិកសរុបចំនួន ២០៥.៣៧០ នាក់ ក៏បានទទួលផលដោយផ្ទាល់ពីដីដែលសំអាតពីគ្រាប់មីនផងដែរ ដែលបានប្រើប្រាស់ដើម្បីសាងសង់ផ្លូវថ្នល់ វត្ត និងសាលារៀន។

ប្រធាន UNDP លោកស្រី ហេឡិន ក្លាក បានធ្វើសុន្ទរកថាបើកទៅកាន់កិច្ចប្រជុំលើកទី ១១ នៃរដ្ឋជាភាគី នៅក្នុងអនុសញ្ញាហាមឃាត់គ្រាប់មីនប្រឆាំងមនុស្ស ដោយអំពាវឲ្យមានការយកចិត្តទុកដាក់ ឲ្យមានការគាំពារតស៊ូមតិកាន់តែខ្លាំងថែមទៀត ដើម្បីកំចាត់មីនប្រឆាំងមនុស្សឲ្យអស់ពីពិភពលោក យើងនេះ។ លោកស្រី ក៏បានជួបជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីពិភាក្សាអំពីបច្ចុប្បន្នភាពរបស់កម្ពុជា និងរបស់ UNDP ក្នុងការបោសសំអាតគ្រាប់មីន។ លោកស្រី បានគូសបញ្ជាក់អំពី ចំណងទាក់ទងជិតស្និទ្ធរវាងការដោះមីន ដោយប្រសិទ្ធភាព និងការរីកចម្រើនក្នុងការសម្រេចគោលដៅ អភិវឌ្ឍន៍សហស្សវត្សរ៍។ លោកស្រីមានប្រសាសន៍ថា សន្និសីទនៅភ្នំពេញ គឺជាឱកាសមួយ ដើម្បីអបអរការរីកចម្រើនក្នុង ការជំនះបាននូវការគំរាមកំហែងពីគ្រាប់មីនប្រឆាំងមនុស្ស និងដើម្បីទទួលស្គាល់ថានៅមានកិច្ចការជាច្រើនដែលនៅសេសសល់ក្នុងការកំចាត់គ្រាប់មីនពីពិភពលោកនេះ។



*លោកស្រី ផុង យើយ អាយុ ៤២ ឆ្នាំ កំពុងបេះផ្លែម្នាស់ក្នុងចំការរបស់គាត់នៅខេត្តបាត់ដំបង។ គាត់ដាំម្នាស់នេះនៅលើដីដែលពីដើមជាចំការមីន តែប្រតិបត្តិការបោសសំអាតមីនបាន រំដោះដីបន្តិចម្តងៗ សំរាប់អ្នកជនបទយកទៅធ្វើកសិកម្មរកចំណូលចិញ្ចឹមគ្រួសារ។*

# ពង្រឹងភាពជាម្ចាស់ ប្រសិទ្ធភាព និងការសម្របសម្រួលជំនួយ

មកទល់ពេលនេះ សមត្ថភាពរបស់រដ្ឋាភិបាលនិងរបស់ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជាក្នុងការដឹកនាំរបៀបវារៈប្រសិទ្ធភាពជំនួយមានការកើនឡើងគួរឲ្យកត់សំគាល់។

អភិក្រមផ្អែកលើកម្មវិធីត្រូវបានបង្កើតឡើងដើម្បីធានាថា ធនធានរបស់ជាតិនិងមកពីក្រៅប្រទេស ត្រូវបានបន្សុីគ្នាពេញលេញជាមួយថវិកាតាមវិស័យរបស់រដ្ឋាភិបាល។ អភិក្រមទាំងនោះជួយពង្រឹងប្រព័ន្ធរបស់រដ្ឋាភិបាលសម្រាប់ការបង្កើតកម្មវិធី ការកសាងផែនការ ការពិនិត្យតាមដាន ការសម្របសម្រួល និងការកៀងគរធនធាននៅក្នុងវិស័យមួយចំនួន ដែលរួមទាំងយេនឌ័រ រដ្ឋបាលជលផល និងព្រៃឈើ និងការដោះមីនផងដែរ។

កម្ពុជាត្រូវបានទទួលស្គាល់នៅកម្រិតពិភពលោកផងដែរថា ជាអ្នកនាំមុខក្នុងការរួមវិភាគទានដល់ការអភិវឌ្ឍទៅអនាគតនៃគោលនយោបាយគ្រប់គ្រងជំនួយ អភិបាលកិច្ច និងការពិនិត្យតាមដាន។ កម្រងទិន្នន័យជំនួយអភិវឌ្ឍន៍ផ្លូវការ ត្រូវបានចាត់ទុកថាជាឧទាហរណ៍មួយនៃទម្លាប់អនុវត្តល្អលើពិភពលោក។



កុមារា ចាន់ វាសនា កំពុងសប់ទឹកដាក់ធុងបង្ហូរតាមប្រព័ន្ធស្រោចស្រពសួនបន្លែ នៅខេត្ត សៀមរាប។ ប្រព័ន្ធស្រោចស្រពនេះជាការឧបត្ថម្ភពីសំណាក់គំរោងមួយរបស់ UNDP សំដៅជួយពង្រីកលទ្ធភាពកសិករក្នុងការបង្កើនផលចិញ្ចឹមគ្រួសារ។

## លទ្ធផលសម្រេចបាន៖

- រដ្ឋាភិបាលបានបញ្ចប់នូវការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងកិច្ចត្រៀមសម្រាប់ធ្វើបច្ចុប្បន្នភាពគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាតិ។ ការពិនិត្យឡើងវិញនោះផ្តោតទៅលើការតាមដាន និងការកំណត់សកម្មភាពសម្រាប់ពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាតិ។
- កិច្ចសន្ទនាអំពីការពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាតិ បានជួយកសាងកុងសង់ស៊ុសលើការវិនិយោគនានាដែលចាំបាច់សម្រាប់ពន្លឿនវឌ្ឍនភាពក្នុងការដោះមីន (CMDG 9)។
- សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ជាង ៩០០ នាក់ ចាប់ផ្តើមប្រើតារាងពិន្ទុ CMDG ដើម្បីត្រៀមរៀបចំផែនការ និងថវិការថ្នាក់ស្រុក និងខេត្ត។
- របាយការណ៍ធនធានមនុស្សដែលផ្សារភ្ជាប់ការអប់រំ និងការហ្វឹកហ្វឺនវិជ្ជាជីវៈបច្ចេកទេសទៅនឹងជំនាញ និងពិពិធកម្មសេដ្ឋកិច្ច ត្រូវបានសម្ពោធក្នុងកិច្ចសកម្មភាពបន្តពីវេទិកាសេដ្ឋកិច្ចកម្ពុជាលើកទី ៤។ ជំហានបន្ទាប់ គឺការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់អភិវឌ្ឍន៍ធនធានមនុស្សក្នុងប្រទេស។
- កិច្ចប្រជុំលើកទី ១១ នៃរដ្ឋសមាជិកអនុសញ្ញាហាមប្រាមគ្រាប់មីនប្រឆាំងមនុស្ស ត្រូវបានរៀបចំឡើងដោយជោគជ័យ។ ប្រទេសហ្វាំងឡង់បានចូលជាសមាជិកអនុសញ្ញានេះ។ ប្រទេសអូទ្រីសបានចុះហត្ថលេខាលើឯកសារគោលការណ៍ភាពជាដៃគូ និងបានរួមវិភាគទានហិរញ្ញវត្ថុដល់សកម្មភាពកំចាត់មីនផងដែរ។
- ទឹកប្រាក់ចំនួន ១៧ លានដុល្លារអាមេរិក ត្រូវបានកៀងគរបន្ថែមទៀតសម្រាប់ទ្រទ្រង់ដល់វិស័យសកម្មភាពមីននៅកម្ពុជា។

# អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ

អភិបាលកិច្ចល្អ គឺជាលក្ខខណ្ឌបឋមសម្រាប់ការអភិវឌ្ឍក្នុងគ្រប់វិស័យនៅកម្ពុជា។ ដោយសារហេតុផលនេះ មួយផ្នែកធំនៃការងាររបស់ UNDP បានផ្តោតលើអភិបាលកិច្ច។

ការយកចិត្តទុកដាក់របស់យើង គឺមកលើការលើកកំពស់យន្តការដែលកាន់តែមានប្រសិទ្ធភាពជាងមុនសម្រាប់ការពិភាក្សា ការចូលរួម ដើម្បីឲ្យពលរដ្ឋគ្រប់គ្នាមានសម្លេងនៅក្នុងការធ្វើសេចក្តីសម្រេចតាមបែបប្រជាធិបតេយ្យ។ ការលើកកំពស់ការចូលរួមរបស់ស្ត្រីនៅក្នុងតំណែងធ្វើសេចក្តីសម្រេចនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ក៏ជាផ្នែកមួយទៀតសំខាន់ដែរ។

មានកិច្ចប្រឹងប្រែងកំពុងអនុវត្តមួយចំនួន ដែលជម្រុញ និងពង្រឹងការពិភាក្សារវាងស្ថាប័នរដ្ឋ និងសង្គមស៊ីវិល ក្រសួងពាក់ព័ន្ធ ព្រឹទ្ធសភា និងក្រុមប្រឹក្សាឃុំ/សង្កាត់។ វេទិកាដ៏សំខាន់មួយផ្សេងទៀតគឺវេទិកានៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ដែលជួយឲ្យប្រជាពលរដ្ឋសំដែងកង្វល់របស់ខ្លួន និងបង្កើនទំនាក់ទំនងជាមួយតំណាងជាប់ឆ្នោតរបស់ខ្លួន អាជ្ញាធរមូលដ្ឋាន ស្ថាប័នរដ្ឋាភិបាល និងសង្គមស៊ីវិល។

## កសាងអភិបាលកិច្ចមូលដ្ឋានដែលឆ្លើយតបតម្រូវការរបស់ពលរដ្ឋបានកាន់តែប្រសើរជាងមុន

នៅឆ្នាំ ២០១១ ជាការឈានដល់ទីបញ្ចប់របស់គម្រោងកិច្ចសហប្រតិបត្តិការអន្តរឃុំ។ គំរោងនេះជម្រុញលើកទឹកចិត្តក្រុមប្រឹក្សាឃុំ ដែលធម្មតាមានថវិកាមានកំរិតសំរាប់ធ្វើការឲ្យសហការគ្នាក្នុងការធ្វើគំរោងអភិវឌ្ឍន៍ ដើម្បីនាំមកនូវផលប្រយោជន៍ជាអតិបរមាដល់សហគមន៍របស់ខ្លួន។ គំរោងនេះផ្តល់ជំនួយបច្ចេកទេស និងមូលនិធិសំរាប់ការងារដែលផ្តោតលើហេដ្ឋរចនាសម្ព័ន្ធខ្នាត និងការផ្តល់សេវាកម្មសាធារណៈក្នុងចំនួន ១២ ខេត្ត។



*អ្នកភូមិកំពុងចូលរួមក្នុងកិច្ចប្រជុំនៅកណ្តាលវាលដើម្បីពិភាក្សាផែនការអភិវឌ្ឍន៍ជាមួយមន្ត្រីឃុំនៅខេត្តកោះកុង។*

វាក៏បានរួមចំណែកផងដែរ ដល់-គោលនយោបាយជាតិ សំរាប់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ ការអភិវឌ្ឍសមត្ថភាពនៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន និងក្នុងការជួយបង្កើតសមាគមក្រុមប្រឹក្សា ថ្នាក់មូលដ្ឋានរបស់កម្ពុជា។

## ការចូលរួម និងភាពជាតំណាង

ក្នុងឆ្នាំ ២០១១ គណបក្សធំពីរ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សសម រង្ស៊ី បានបង្កើតយុទ្ធសាស្ត្រយេនឌ័រ និងកំណត់ចំណុចដៅ ៣០ ភាគរយ និង ១៥ភាគរយ រៀងៗខ្លួន ដើម្បីបង្កើនបេក្ខភាពស្ត្រីនៅក្នុងការបោះឆ្នោត ក្រុមប្រឹក្សាឃុំឆ្នាំ ២០១២។

ជាមួយគ្នានេះដែរ កំណែទម្រង់ការបោះឆ្នោតបាននាំឲ្យមានការពន្យារសុពលភាពអត្តសញ្ញាណប័ណ្ណរបស់ពលរដ្ឋដំណាក់កាលចុះឈ្មោះបោះឆ្នោត និងការដាក់ឲ្យប្រើនូវទម្រង់បែបបទបណ្តោះអាសន្នសំរាប់អត្តសញ្ញាណប័ណ្ណដែលមានលក្ខណៈប្រសើរជាងមុន។

UNDP បានផ្តោតជាបឋមលើការតស៊ូមតិ ជាពិសេសដែលទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោតពីក្នុងចំណោមក្រុមអ្នកទន់ខ្សោយ ដូចជា ជនពិការ ជនជាតិដើម ក្រុមជនភាគតិច ជនអនាថា និងកម្មករចំណាកស្រុក។

## បង្កើតលំហសម្រាប់ការវែកញែកបែបប្រជាធិបតេយ្យ

យុវជនកម្ពុជាត្រៀមខ្លួនចូលរួមយ៉ាងសកម្មក្នុងជីវភាពសង្គមរបស់ប្រទេស។ ការសិក្សាឈ្មោះ" ចំណេះដឹង, តរិយាបថ និងការប្រព្រឹត្ត" (Knowledge, Attitude and Practices (KAP) Study) ដែលបានធ្វើឡើងកាលពីឆ្នាំ ២០១០ ដើម្បីស្វែងយល់អំពីការចូលរួមរបស់យុវជនក្នុងជីវភាពសង្គមបានរកឃើញថា យុវជនមានសុទិដ្ឋនិយមអំពីអនាគតប្រទេសរបស់ខ្លួន ប៉ុន្តែនៅជួបប្រទះឧបសគ្គច្រើននៅឡើយចំពោះការចូលរួមរបស់ពួកគេ។

ប្រព័ន្ធព័ត៌មានផ្តល់នូវវេទិកាមួយសម្រាប់យុវជន ដើម្បីទាក់ទងជាមួយសង្គមទាំងមូល។ ប្រព័ន្ធព័ត៌មានក៏ជាមធ្យោបាយ ដ៏មានប្រសិទ្ធភាពសម្រាប់ផ្តល់ការអប់រំដល់ពលរដ្ឋតាមវិធីដែលផ្តល់នូវបរិយាកាសកំសាន្ត និងមិនផ្លូវការផងដែរ និងជាគំរូអំពីគុណធម៌ទិដ្ឋភាពនៃការចូលរួមដើម្បីលោកទឹកចិត្តឲ្យមានភាពចម្រុះ និងឌីណាមិកក្នុងចំណោមយុវជននៅកម្ពុជា។ មែនអី! ដែលជាកម្មវិធីតាមវិទ្យុដែលទទួលការទូរស័ព្ទចូល បានដំណើរការចាប់ពីខែមេសា ដោយមាន ២៥ ភាគ អំពីប្រធានបទអប់រំប្រជាពលរដ្ឋ ដូចជា របៀបធ្វើការជាក្រុម ការសំដែងមតិផ្ទាល់ខ្លួន និងការបោះឆ្នោត។

កម្មវិធីសមធម៌ប្រចាំសប្តាហ៍តាមទូរទស្សន៍បានបន្តផលិតនិងចាក់ផ្សាយការសំដែងនានាដែលគូសបញ្ជាក់អំពីបញ្ហាដែលមានសារៈសំខាន់ខាងនយោបាយ សង្គម សេដ្ឋកិច្ច និងបរិស្ថានចំពោះកម្ពុជា។ ការអង្កេតនៅឆ្នាំ ២០១១ បានឲ្យដឹងថា ការទទួលយកកម្មវិធីនេះក្នុងចំណោមអ្នកកសាងគោលនយោបាយ សមាជិកសភា និងអ្នកពាក់ព័ន្ធដទៃទៀតខាងផ្នែកប្រជាធិបតេយ្យដែលសម្រាប់ពួកគេ កម្មវិធីនេះ គឺជាប្រភពដ៏សំខាន់មួយនៃព័ត៌មានអំពីបញ្ហាបច្ចុប្បន្នភាពរបស់កម្ពុជា។

បណ្តាញប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពមួយ ត្រូវបានបង្កើតសំរាប់ជនជាតិដើមភាគតិចនៅទូទាំងប្រទេស។ ការពិគ្រោះយោបល់មួយអំពីវិទ្យុជាភាសាជនជាតិដើម និងប្រព័ន្ធព័ត៌មានសហគមន៍នៅកម្ពុជា គឺជាគំរូមួយដែលមានប្រយោជន៍សម្រាប់ចែករំលែកព័ត៌មានជាមួយមន្ត្រីរដ្ឋាភិបាល អំពីគំរូខុសៗគ្នានៃភាសាជនជាតិដើម និងព័ត៌មានសហគមន៍នៅកម្ពុជា។

*លទ្ធផលសម្រេចបាន ៖*

- *សម្ព័ន្ធភាពជាតិ ឃុំ/សង្កាត់ ដែលតំណាងឲ្យ ១.៦៣៣ ឃុំ និងសង្កាត់ ដែលបានបង្កើយផែនការយុទ្ធសាស្ត្រលើកទីពីរ (២០១១-២០១៥) របស់ខ្លួន។*
- *សមាគមឃុំ/សង្កាត់ នៅថ្នាក់ខេត្ត ត្រូវបានបង្កើតនៅក្នុងខេត្តទាំង ២៣ និងរាជធានី។*
- *សម្ព័ន្ធភាពជាតិឃុំ/សង្កាត់ គឺជាសមាជិកអចិន្ត្រៃយ៍នៃអនុគណៈកម្មាធិការនៅក្នុងគណៈកម្មាធិការ-ជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងដើរតួយ៉ាងសំខាន់មួយនៅក្នុងការពិភាក្សាគោលនយោបាយ និងដំណើរការកែទម្រង់ស្តីពីវិមជ្ឈការ និងអភិបាលកិច្ចនៅមូលដ្ឋាន។*
- *ប្រព័ន្ធគ្រប់គ្រងនិងបទប្បញ្ញត្តិនានា ត្រូវបានបង្កើតឡើង ដើម្បីជួយរដ្ឋបាលនៅថ្នាក់ក្រោមជាតិ និងសម្ព័ន្ធភាពជាតិ ធ្វើការឆ្លើយតបបានប្រសើរជាងមុនទៅនឹងតម្រូវការរបស់អតិថិជនខ្លួន និងដើម្បីលើកគម្រោងគ្រប់គ្រងពិនិត្យតាមដាន និងរាយការណ៍អំពីសកម្មភាពលទ្ធផលនានា និងការប្រើប្រាស់ធនធាន។*

## ស្ពានថ្មីសម្រួលការធ្វើដំណើររបស់អ្នកភូមិ



ស្ពានចាស់ឆ្លងព្រែកកំពង់ស្តំខេត្តកោះកុង។

**ខេត្តកោះកុង** - នៅពេលអ្នកស្រី សូ ផន សម្រាលកូនទីមួយកាលពីបីឆ្នាំមុន គាត់ត្រូវជិះម៉ូតូឌុបពីផ្ទះរបស់គាត់ទៅកាន់ព្រែកមួយដែលនៅទីនោះ គាត់ត្រូវផ្ទេរទៅឡើងជិះទូកឆ្លង។ ទៅដល់ត្រើយម្ខាង គាត់ត្រូវគេលើកដាក់លើរ៉ឺម៉កម៉ូតូមួយ ឆ្ពោះទៅកាន់មណ្ឌលសុខភាពនៅក្នុងឃុំបឹងព្រាវ។ ការធ្វើដំណើរនេះអ្នកស្រីត្រូវចំណាយពេលពីរម៉ោង។

លោកស្រី សូ ផន រស់នៅឃុំជ្រោយស្វាយ ខេត្តកោះកុង បាននិយាយរំលឹកពីបទពិសោធន៍របស់គាត់ថា "ការធ្វើដំណើរនោះយ៉ាប់ខ្លាំងណាស់"។

ការឆ្លងព្រែកកំពង់ស្តុំដែលមានទទឹង ៤០ម៉ែត្រ នេះបច្ចុប្បន្នត្រូវបានធ្វើអោយមានភាពស្រួលដោយ ស្ពានបេតុងមួយដែលសាងសង់ឡើងដោយគម្រោងសហការរវាង UNDP និងEuropean Union ដែលមានឈ្មោះថា "ពង្រឹងអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការនៅកម្ពុជា"។

ចំពោះអ្នករស់នៅឃុំជ្រោយស្វាយ និងបឹងព្រាវ ចំនួន ១០០០០នាក់ ដែលត្រូវខ័ណ្ឌចែកដោយព្រែកនេះ ការប្រព្រឹត្តនៃជីវភាពប្រចាំថ្ងៃត្រូវការពេលវេលាតិចជាងមុន ក្រោយពីស្ពាននេះត្រូវបើកអោយប្រើប្រាស់កាលពីខែមិនា ឆ្នាំ២០១១។

ពីមុនធ្លាប់មានស្ពានឈើដែរ ប៉ុន្តែ ស្ពាននោះមានគ្រោះថ្នាក់ណាស់ សូម្បីតែចំពោះអ្នកថ្មើរជើងក៏អាចមានគ្រោះថ្នាក់ដែរ។ កម្រាលស្ពាននេះមានសុទ្ធតែប្រហោងដោយសារក្តារស្ពានពុកផុយអស់។ ស្ពានទាំងមូលគ្មានលំនឹងទេ។ អ្នកជិះម៉ូតូត្រូវដាក់ម៉ូតូរបស់ខ្លួននៅលើដដែលមានទូកពីរចងផ្គោបគ្នាដោយកម្រាលឈើមួយផ្ទាំងដើម្បីឆ្លងព្រែកនេះដោយបង់ប្រាក់ចំនួន ៥០០រៀល សម្រាប់ការឆ្លងកាត់មួយជើង (ប្រហែលជា ០,១២ ដុល្លារ)។ ចំនួនទឹកប្រាក់នេះតិចតួចណាស់ ប៉ុន្តែនៅក្នុងប្រទេសមួយ ដែលបន្ទាត់នៃភាពក្រីក្រមានប្រហែលជា ០,៦០ ដុល្លារ ក្នុងមួយថ្ងៃថ្លៃធ្វើដំណើរនេះអាចមានតម្លៃខ្ពស់ សម្រាប់អ្នកភូមិ។

លោក ហៃ ស៊ីន មេឃុំជ្រោយស្វាយ បានអោយដឹងថា "គេត្រូវចំណាយពេលជាច្រើន ដើម្បីនាំអ្នកជំងឺទៅកាន់មន្ទីរពេទ្យឬដឹកនាំទំនិញទៅកាន់ទីផ្សារ។ នៅពេលយប់អ្នកដឹកទំនិញមិនអាចឆ្លងស្ពាននេះបានទេមានអ្នកខ្លះធ្លាក់ទៅក្នុងស្ទឹងជាមួយម៉ូតូ។ ហេតុដូច្នេះហើយបានជាស្ពាននេះ ជាតម្រូវការជាអាទិភាពបំផុតរបស់អ្នកស្រុក"។

នៅឆ្នាំ២០១០ លោក ហៃ ស៊ីន បានអញ្ជើញមេឃុំបឹងព្រាវ ដែលនៅជិតដើម្បីប្រមូលផ្តុំថវិកាពីគម្រោងថវិកាមូលដ្ឋានដ៏ស្តួចស្តើងរបស់ខ្លួនរួចហើយរៀបចំសំណើរួមគ្នាដើម្បីស្វែងរកមូលនិធិពីសហប្រតិបត្តិការអន្តរឃុំ។គម្រោងការណ៍របស់ពួកគេទទួលបានជោគជ័យបានទទួលទឹកប្រាក់ចំនួន ៤០.០០០ ដុល្លាអាមេរិក ពីសហប្រតិបត្តិការអន្តរឃុំដើម្បីសាងសង់ស្ពាននេះ។



ស្ពានថ្មត្រូវបានជំនួសស្ពានឈើចាស់សម្រាប់ឆ្លងព្រែកកំពង់ស្តំជួយសម្រួលដល់ការធ្វើដំណើររបស់អ្នកភូមិ។

លោកពោលថា "ក្នុងនាមក្រុមប្រឹក្សាឃុំយើងមិនគួរគិតតែអំពីសហគមន៍របស់យើងផ្ទាល់ទេ។ យើងអាចធ្វើការរួមគ្នាដើម្បីនាំមកនូវផលប្រយោជន៍ សម្រាប់ប្រជាជនទាំងអស់"។

អ្នកស្រី សូ ផន ដែលជិតសម្រាលកូនទីពីររបស់គាត់បានថ្លែងថា "ឥឡូវនេះគ្មានទូកដែលត្រូវបង់ថ្លៃឆ្លងព្រែកទៀតទេ"។ គាត់និយាយថា គាត់សប្បាយចិត្តណាស់ដែលគាត់អាចចំណាយពេលតែ ៣០នាទីប៉ុណ្ណោះ ធ្វើដំណើរតាមផ្លូវគោកទៅកាន់មន្ទីរ ពេទ្យដោយសារតែស្ពានថ្មីនេះ។

## បង្អិតសាលារៀនឲ្យមកនៅជិតផ្ទះ



អាគារសិក្សាមួយខ្នងដែលបានសាងសង់ដោយគម្រោងឧបត្ថម្ភពី សហគមន៍អឺរ៉ុប បានជួយបង្កើនលទ្ធភាពទទួលការសិក្សារបស់ក្មេងជនបទនៅប៉ែកពាយ័ព្យប្រទេសកម្ពុជា។

សូយ ភាព ជាម្តាយដែលមានកូន ៧នាក់ បានធ្វើការសម្រេចចិត្តយ៉ាងលំបាកកាលពីប៉ុន្មានឆ្នាំមុននេះ នៅពេលដែលកូនស្រីរបស់ គាត់ម្នាក់បានចាប់ផ្តើមចូលរៀនថ្នាក់មធ្យមសិក្សា។ ដោយគ្មានសាលារៀននៅក្នុងភូមិនៅខេត្តបន្ទាយមានជ័យ គាត់សម្រេចចិត្តបញ្ជូនកូនស្រីទៅរស់នៅជាមួយជីដូនរបស់កូន នៅខេត្តបាត់ដំបង ដែលស្ថិតនៅចម្ងាយ ១៣០គ.ម ពីផ្ទះ ដើម្បីកូនអាចបន្តការសិក្សា។

ប៉ុន្តែ ម្តាយដែលមានអាយុ ៣៩ឆ្នាំរូបនេះ ពុំចាំបាច់ជ្រើសយកការសេម្រេចចិត្តបែបបនេះទៀតឡើយ សម្រាប់កូនស្រីបន្ទាប់របស់គាត់ ដោយសារបច្ចុប្បន្ននេះសាលាមធ្យមសិក្សាពង្រុបានបើកទ្វារដំណើរការហើយ។

កាលពីមុន កុមារជាច្រើនត្រូវធ្វើដំណើរលើផ្លូវចម្ងាយ ៨គ.ម ពីដងក្នុងមួយថ្ងៃ ដើម្បីទៅរៀនថ្នាក់មធ្យមសិក្សានៅក្នុងឃុំមួយផ្សេងទៀត។ សិស្សខ្លះបោះបង់ចោលសាលារៀនដើម្បីឃ្វាលគោ ឬ ធ្វើការនៅតាមស្រែជាមួយឪពុកម្តាយរបស់ពួកគេ។ ក្នុងការឆ្លើយតបទៅនឹងការចាំបាច់របស់កុមារ មន្ត្រីនៅមូលដ្ឋានបានគ្រោងសាងសង់សាលារៀនថ្មីមួយទៀត។

គឹម មន ប្រធានឃុំទួលពង្រ បានចាត់ចែងរកបានដីមួយកន្លែងដែលទើបតែបានដោះមីនរួច។ ប៉ុន្តែជាជាងអនុវត្តតែឯង គាត់បានសម្រេចចិត្តចូលរួមជាមួយសមាជិក្រុមប្រឹក្សាឃុំនៅក្នុងឃុំសំពណ៌ដែលនៅជិតខាង។ លោក គឹម មន ពោលថា "នៅពេលយើងដឹងថាមានមូលនិធិពីគម្រោងសហប្រតិបត្តិការអន្តរឃុំ ឃុំយើងទាំងពីរបានធ្វើការជាមួយគ្នា ដើម្បីស្នើសុំប្រាក់មូលនិធិនេះ។ បន្ទាប់មកយើងបានទទួលប្រាក់នោះ។"

សំណើពីឃុំទាំងពីរបានទទួលថវិកាគាំទ្រចំនួន ៣៧.៨២០ដុល្លាពីមូលនិធិ ICC។ ពួកគេក៏បានស្វែងរកប្រាក់ចំនួន ៣០០ដុល្លាជាបន្ថែមពីអ្នកភូមិផងដែរ។ ប៉ុន្តែចំនួនសរុបបានគ្រប់សម្រាប់តែសាងសង់អាគារដែលមាន៤បន្ទប់ ក្នុងចំណោម ១០បន្ទប់តែប៉ុណ្ណោះ ដែលជាចំនួនពួកគេត្រូវការជាចាំបាច់។ ដូច្នេះឃុំទាំងពីរត្រូវតែស្វែងរកថវិកាថែមទៀត។

ដោយសារតែពួកគេគោរពបានតាមលក្ខខណ្ឌចំបងៗនៃដំណើរការដេញថ្លៃប្រកបដោយតម្លាភាព ឃុំទាំងពីរអាចទាក់ទាញមូលនិធិ ៧០.០០០ដុល្លាជាបន្ថែម ពីយុទ្ធនាការដោះមីន (CMC) ដែលជាក្រុមដោះមីនសម្រាប់មនុស្សធម៌មួយ ដើម្បីបង្ហើយសាលារៀននេះ។

ហ៊ីរ៉ូស៊ិ អាកេ នាយក CMC ប្រចាំនៅកម្ពុជាបានពោលថា "ក្រុមប្រឹក្សាមូលដ្ឋាននៅកម្ពុជា នៅតែមានភាពទន់ខ្សោយនៅឡើយខាងផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ ដូច្នេះប្រសិនបើពួកគេធ្វើការជាមួយគ្នាដូចជាអង្គភាពតែមួយ ពួកគេនឹងអាច ផ្តល់ប្រយោជន៍កាន់តែច្រើនដល់សហគមន៍របស់ពួកគេ។

លោកមានប្រសាសន៍ថា ក្រុមរបស់គាត់បានសម្រេចគាំទ្រ ដល់កិច្ចផ្តួចផ្តើមនេះ ដោយសារតែកម្រិតនៃទំនុកចិត្ត និងការដេញថ្លៃប្រកបដោយតម្លាភាព ដែលឃុំទាំងពីរនេះបានបង្ហាញឲ្យឃើញ។

សូយ ភាពសប្បាយចិត្តណាស់ដែលអាចឲ្យកូនស្រីនៅជិតខ្លួន។ គាត់បានពោលថា "សាលារៀនថ្មីនេះស្ថិតនៅជិតផ្ទះខ្ញុំណាស់ឥឡូវនេះ ដូច្នេះ ខ្ញុំនឹងអាចបញ្ជូនកូនទៅរៀននៅទីនោះជាជាងទៅបាត់ ដំបង"។



សិស្សកំពុងរៀនក្នុងថ្នាក់ដែលបានសាងសង់ឡើងដោយគម្រោងឧបត្ថម្ភពីសហគមន៍អឺរ៉ុប ។

# បរិស្ថាន ថាមពល និង ការប្រែប្រួលអាកាសធាតុ

*"រូបភាពជនរងគ្រោះទឹកជំនន់គ្រប់គ្រាន់ហើយសម្រាប់យើងទាំងអស់គ្នា ដើម្បីចាត់វិធានការជាបន្ទាន់ក្នុងការកាត់បន្ថយភាពឈឺចាប់ទាំងនេះ និងពង្រឹងភាពធន់ទ្រាំរបស់ប្រជាជន និងសមត្ថភាពបន្សាំនៅក្រោមលក្ខខណ្ឌប្រែប្រួលអាកាសធាតុ។ ប្រសិនបើយើងត្រូវគិតអំពីកូនចៅជំនាន់ក្រោយរបស់យើង យើងត្រូវតែប្តូរលំនាំនៃការអភិវឌ្ឍទៅរកលំនាំដែលបៃតងជាងមុន ពោល គឺគំរូដែលបំភាយកាបូនកម្រិតទាប និងដែលកាន់តែធន់ទ្រាំទៅនឹងអាកាសធាតុ"។*

*ឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន*

បរិស្ថាននៅកម្ពុជាកំពុងស្ថិតក្រោមសម្ពាធកាន់តែខ្លាំងឡើងៗ ដោយសារការអភិវឌ្ឍយ៉ាងឆាប់រហ័ស និងកង្វល់ថ្មីៗ ដូចជា ការប្រែប្រួលអាកាសធាតុជាដើម។

អាទិភាពគួរតែមានលើការអភិវឌ្ឍធនធានមនុស្ស និងស្ថាប័ន ការស្រាវជ្រាវ ការអនុវត្តបច្ចេកវិទ្យាសមស្រប និងធនធានហិរញ្ញវត្ថុ ក្នុងគោលដៅពង្រឹងសមត្ថភាព ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាពទៅនឹងការប្រែប្រួលអាកាសធាតុ។ កិច្ចការនេះត្រូវតែធ្វើឡើងនៅក្នុងវិស័យនានា ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ ដូចជា កសិកម្ម ធនធានទឹក ជលផល ព្រៃឈើ ថាមពល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

ទឹកជំនន់បង្កការខូចខាតមកលើប្រជាពលរដ្ឋចំនួន ១,៥ លាននាក់ និងបានបំផ្លាញយ៉ាងហោចណាស់ដំណាំ ៩,៤% នៅឆ្នាំ ២០១១ ដែលនាំឲ្យមានកំណើនការយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនៅក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ។

ដោយសារតែគ្រោះមហន្តរាយធម្មជាតិ គឺជាឥទ្ធិពលយ៉ាងខ្លាំងក្លាបណ្តាលពីការប្រែប្រួលអាកាសធាតុ កិច្ចការនានាក៏កំពុងតែអនុវត្ត ដើម្បីបង្កើនការត្រៀមលក្ខណៈ និងភាពធន់ទ្រាំរបស់សហគមន៍ផងដែរ។ ជំនួយឥតសំណងចំនួន ៤,៣ លានដុល្លារអាមេរិក ត្រូវបានអនុម័តរួចមកហើយសម្រាប់កិច្ចផ្តួចផ្តើម ភាពធន់ទ្រាំរបស់សហគមន៍ចំនួន ៣៤១ ហើយការប្រែប្រួលអាកាសធាតុ ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការវិនិយោគឃុំរបស់ឃុំចំនួន ៨៥។

## ការអភិវឌ្ឍ និងការប្រើប្រាស់ធនធានធម្មជាតិ

ការគ្រប់គ្រងបានសមស្របនូវធនធានទឹក កសិកម្ម ព្រៃឈើ និងជលផល មានសារៈសំខាន់ជាស្នូលសម្រាប់សហគមន៍នៅកម្ពុជា ក្នុងការលៃលក ជាមួយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។



*ទុយោនាំទឹកពីក្នុងប្រឡាយមួយទៅស្រោចស្រពវាលស្រែក្នុងខេត្តស្វាយរៀង។ ប្រឡាយនេះត្រូវបានស្តារតាមរយៈគម្រោងមួយរបស់ UNDP សំដៅជួយកសិករបង្កើនទិន្នផលស្រូវ។*

ការកសាងផែនការ និងសកម្មភាពរបស់រដ្ឋបាលមូលដ្ឋាន ក៏មានសារៈសំខាន់ក្នុងការជួយអ្នកក្រឲ្យមានភាពធន់ទ្រាំ មិនត្រឹមតែក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេប៉ុន្តែថែមទាំងនៅក្នុងការស្តារឡើងវិញ នូវស្ថានភាពចេញពីគ្រោះមហន្តរាយធម្មជាតិ ឬវិបត្តិសេដ្ឋកិច្ចណាមួយទៅអនាគតផងដែរ។

សកម្មភាពបទល្មើសព្រហ្មទណ្ឌ ក្នុងព្រៃឈើជាបញ្ហាធំមួយ។ ក្នុងឆ្នាំ ២០១១ មន្ត្រីល្បាតព្រៃបាន ទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសល្បាតព្រៃ ត្រួតពិនិត្យសត្វព្រៃ និងធ្វើសេចក្តីរាយការណ៍អំពីបទល្មើស

ក្នុងវិស័យព្រៃឈើ ដូចជាការកាប់ឈើខុសច្បាប់ និងការចាប់សត្វព្រៃជាដើម។ ការតស៊ូមតិជាប់ជាប្រចាំ បានកាត់បន្ថយការកាប់ឈើល្មើសច្បាប់នៅក្នុងព្រៃការពារនៅខេត្តព្រះវិហារ ហើយបានជួយគ្រប់គ្រងការគំរាមកំហែងពីដីសម្បទានសង្គមថ្មីៗសម្រាប់យោធាផងដែរ។

ចំនួនគ្រួសារចូលរួមក្នុងកម្មវិធីដាំស្រូវការពារសត្វត្រយ៉ងក្នុងវាលទំនាប នាប៉ែកខាងជើងប្រទេសកម្ពុជា មានការកើនឡើងជិតបីដង គឺរហូតដល់ ១៨,៧% ក្នុងឆ្នាំ ២០១០-២០១១ ពី ៦,៤% នៅក្នុងឆ្នាំ ២០០៨-២០០៩។ ជាលទ្ធផល តម្លៃសរុបបានមកពីការលក់អង្ករដែលគេឲ្យឈ្មោះថា អង្ករសត្វត្រយ៉ង ក្នុងឆ្នាំ២០១១ កើនជិតទ្វេដង គឺរហូតទៅដល់ ៦០.០០០ ដុល្លារអាមេរិក ប្រៀបនឹង ៣៦.៦០០ ដុល្លារអាមេរិក ក្នុងឆ្នាំ ២០១០។

គម្រោង "ការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព" ត្រូវបានសម្ពោធនៅឆ្នាំ ២០១១ ដោយផ្តោតលើខេត្តចំនួនបួននៅកម្ពុជា ៖ កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ និងបាត់ដំបង។ ខេត្តទាំងនេះជាជម្រកព្រៃឈើដែលមានជីវៈចម្រុះមានតម្លៃជាសកល និងដើរតួជាអាងស្តុកកាបូនធំផងដែរ។ គោលបំណងមួយរបស់គម្រោងនេះ គឺបង្កើត និងគ្រប់គ្រងមុខរបរក្នុងមូលដ្ឋានព្រៃសហគមន៍ប្រមាណជា ៣០ និងក្នុងតំបន់ព្រៃការពារចំនួន ១០។ អ្នកស្រុក ជាពិសេសស្ត្រីនឹងទទួលបាននូវការហ្វឹកហ្វឺនក្នុងការផលិតចង្ក្រានប្រើថាមពលតិច ដើម្បីលក់យកចំណូល និងជួយកាត់បន្ថយតម្រូវការអុសដុតផង។ គម្រោងនេះនឹងរួមចំណែកដល់កម្មវិធីព្រៃឈើជាតិរបស់រដ្ឋាភិបាលដែលសំដៅបង្កើតឲ្យបានព្រៃសហគមន៍ចំនួន ២ លានហិកតា នៅទូទាំងប្រទេសដល់ឆ្នាំ ២០២៩។

## ការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុត្រូវបានគេរំពឹងទុកថា នឹងបន្ថែមទំងន់ទៅលើភាពប្រឈមក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជាថែមទៀត។ ក្នុងន័យជួយដល់រដ្ឋាភិបាលក្នុងការលៃលកជាមួយភាពប្រឈមទាំងនោះ មូលនិធិត្រាស់មួយនៃសម្ព័ន្ធភាពកម្ពុជាសំរាប់ការប្រែប្រួលអាកាសធាតុ (Cambodia Climate Change Trust Fund) ត្រូវបានបង្កើតឡើងក្នុងភាពជាដៃគូរវាង UNDP សហភាពអឺរ៉ុប ប្រទេសស៊ុយអែត និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិប្រទេស ដាណឺម៉ាក។ ផែនទីបង្ហាញផ្លូវមួយសំរាប់ឈានទៅបង្កើតផែនការ យុទ្ធសាស្ត្រកម្ពុជាសំរាប់ការប្រែប្រួលអាកាសធាតុត្រូវបានបង្កើតឡើង ដើម្បីជាជំនួយដល់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុក្នុងវិស័យអភិវឌ្ឍន៍សំខាន់ៗ។

មូលនិធិត្រាស់នេះបានផ្តល់ប្រាក់ឲ្យគំរោងចំនួន ៨ រួចមកហើយ ក្នុងគំរោង ៦ ជារបស់អង្គភាពរដ្ឋាភិបាល និង គំរោង ២ ទៀតជារបស់អង្គការមិនមែនរដ្ឋាភិបាល។ គំរោងទាំង ៨ នោះធ្វើការទៅលើខេត្តចំនួន ១០ ក្នុងការលៃលកបញ្ហាមួយចំនួន មានផែនការ អភិវឌ្ឍន៍ទីប្រជុំជន ការគ្រប់គ្រងជលផល ការគ្រប់គ្រងតំបន់ការពារ ការគ្រប់គ្រងព្រៃសហគមន៍ ការអភិវឌ្ឍសហគមន៍ ការផលិតស្រូវ និង ការរៀបចំផែនការថ្នាក់ក្រោមជាតិ។

នៅខែតុលា ២០១១ វេទិកាជាតិលើកទីពីរស្តីពីការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើឡើង ហើយធ្វើការសង្កត់បញ្ជាក់បន្ថែម អំពីភាពចាំបាច់ឲ្យមានការឆ្លើយតបជាលក្ខណៈទូលំទូលាយ និងពួតដៃគ្នាទៅនឹងឥទ្ធិពលការប្រែប្រួលអាកាសធាតុ។

ការសម្ពោធផ្សព្វផ្សាយរបាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុជាផលិតផលពុទ្ធិមួយនៅលើប្រធាន បទនេះនៅកម្ពុជា ដែលអាចប្រើជាឧបករណ៍តស៊ូមតិមួយមានប្រយោជន៍សំរាប់ការរៀបចំផែនការនិងការធ្វើសេចក្តីសំរេចចិត្តផ្នែក នយោបាយទៀតផង។

## ជំរុញការអនុវត្តទំលាប់ល្អៗក្នុងវិស័យកសិកម្មធន់នឹងការប្រែប្រួលអាកាសធាតុ

មូលនិធិបរិស្ថានសាកល (Global Envrionment Facility) និង UNDP បានផ្តល់មូលនិធិគំរោងមួយដែលមានឈ្មោះថា Cambodia National Adaptation Programme

### លទ្ធផលសម្រេចបាន៖

- វេទិកាជាតិលើកទីពីរស្តីពីការប្រែប្រួលអាកាសធាតុ កាលពីខែតុលា បាននាំមកបញ្ចូលគ្នានូវភ្នាក់ងារអនុវត្តការងារប្រែប្រួលអាកាសធាតុ អ្នកកសាងគោលនយោបាយ និងអ្នកកសាងផែនការ។ លទ្ធផលពីវេទិកានេះ គឺថាការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានទទួលស្គាល់ថាជាផ្នែកមួយនៃកិច្ចការអភិវឌ្ឍន៍ ដែលទាមទារឲ្យមានការឆ្លើយតបក្នុងវិស័យជាច្រើន។
- អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងស្ថាប័នរដ្ឋាភិបាលសរុបប្រមាណ ៥០ បានទទួលជំនួយឥតសំណង ៥០.០០០ ដុល្លារ និងជំនួយខ្នាតមធ្យម ៣០០.០០០ ដុល្លារ ដើម្បីលើកកំពស់ការបន្សាំផ្អែកលើសហគមន៍ និងវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅតាមមូលដ្ឋាន ជាក់ស្តែងនៅទូទាំងប្រទេសកម្ពុជា។ អន្តរាគមន៍ទាំងនេះនឹងបង្កើតជាការអនុវត្តល្អៗ និងមេរៀនដែលមានគោលដៅផ្តល់ឥទ្ធិពលមកលើគោល-នយោបាយប្រែប្រួលអាកាសធាតុ។
- គម្រោងជំនួយខ្នាតតូចចំនួន ៤៦ សម្រាប់ជម្រុញការបន្សាំរបស់សហគមន៍ទៅនឹងការប្រែប្រួលអាកាសធាតុ ត្រូវបានអនុម័ត។
- ភូមិចំនួន ៣៥៣, ឃុំចំនួន ៩៧, ស្រុកចំនួន ៤៨ និងខេត្តចំនួន ១៨ ក្នុងប្រទេសកម្ពុជា បានទទួលការគាំទ្រសម្រាប់អនុវត្តបង្ហាញអំពីបច្ចេកទេសធន់ទ្រាំនឹងអាកាសធាតុនៅថ្នាក់សហគមន៍ និងគ្រួសារ។
- សមាជិកក្រុមប្រឹក្សាឃុំចំនួន ៩៧ មានការយល់ដឹងប្រសើរជាងមុនអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ តាមរយៈការចូលរួមនៅក្នុងការវាយតម្លៃភាពងាយរងគ្រោះដោយហានិភ័យ (VRA), សិក្ខាសាលាបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ និងការបង្កើត និងអនុវត្តគម្រោងបន្សាំនៅមូលដ្ឋាននៅក្នុងឃុំរបស់ពួកគេរៀងៗខ្លួន។ ភាពជាដៃគូ និងភាពជាម្ចាស់ត្រូវបានបង្កើតឡើងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងក្នុងចំណោមតំណាងអង្គការសង្គមស៊ីវិលតាមរយៈកិច្ចប្រជុំ និងសិក្ខាសាលាមួយចំនួន។

of Actions (NAPA) ដោយផ្តោតលើការបង្កើតភាពធន់ទ្រាំការប្រែប្រួលអាកាសធាតុ ក្នុងវិស័យកសិកម្ម និងធនធានទឹក។ គំរោងនេះត្រូវបានអនុវត្តន៍ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹកនិង ឧតុនិយម និងក្រសួងកិច្ចការនារី។

ការវាយតម្លៃភាពងាយរងគ្រោះដោយហានិភ័យមួយដែលធ្វើឡើងនៅឆ្នាំ ២០១១ បាននាំឲ្យមានការធ្វើសមាហរណកម្ម អាទិភាពការប្រែប្រួលអាកាសធាតុនានាទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ (២០១១-២០១៤) របស់ខេត្តគោលដៅពីរ គឺខេត្ត ក្រចេះ និង ខេត្តព្រះវិហារ។

បន្ថែមលើនោះ កម្មវិធីបង្រៀនជាលើកដំបូងមួយស្តីពីប្រព័ន្ធធារាសាស្រ្តធន់ទ្រាំការប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើង ហើយវគ្គហ្វឹកហ្វឺនក៏ត្រូវបានផ្តល់ជូនមន្ត្រីរដ្ឋាភិបាលដែលទទួលបន្ទុករៀបចំផែនការធារាសាស្រ្ត។

## កម្មវិធីបន្សាំសហគមន៍

ជាមួយមូលនិធិពីរដ្ឋាភិបាលស៊ុយអែត និងទីភ្នាក់ងារជំនួយអន្តរជាតិអូស្ត្រាលី UNDP តាមរយៈកម្មវិធីជំនួយគំរោងខ្នាតតូច បានផ្តល់មូលនិធិដល់គំរោងចំនួន ៤៦ គំរោង ក្នុងនោះ ៣៨ ជាគំរោងរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិង ៨ ផ្សេងទៀត ជាគំរោងអង្គការសហគមន៍មូលដ្ឋាន។ គំរោងទាំងនោះអនុវត្តន៏វិធានការសំដៅកសាងភាពធន់ទ្រាំរបស់សហគមន៍ដែលងាយរងគ្រោះពី សំណាក់ឥទ្ធិពលការប្រែប្រួលអាកាសធាតុ។ សហគមន៍ទាំងនោះមាននៅក្នុងភូមិចំនួន ៣៥៣ ឃុំ ៩៧ ស្រុក ៤៨ ក្នុងខេត្ត ១៨ នៃប្រទេសកម្ពុជា។ តាមរយៈគំរោងទាំងនោះ ៖

- គ្រួសារចំនួន ៦០.១៧៣ ទទួលបានផលប្រយោជន៍ពីការស្តារប្រព័ន្ធធារាសាស្រ្តខ្នាតតូច (សំរាប់ស្រោចស្រពស្រូវប្រាំង ១១.៩៧៨ ហិកតា និងស្រូវវស្សា ២៩.៨១៧ ហិកតា)
- ស្រះសហគមន៍និងគ្រួសារចំនួន ១៨៥ ត្រូវបានស្តារឡើងវិញ
- ក្រុមអ្នកប្រើប្រាស់ទឹកសហគមន៍ចំនួន ៦៩ ក្រុម ត្រូវបានបង្កើតឡើង
- ក្រុមស្ត្រីសន្សំប្រាក់ចំនួន ២៧០ ក្រុម ធនាគារស្រូវចំនួន ៤៧ និង ធនាគារគោចំនួន ១៥ ត្រូវបានបង្កើតឡើង
- ក្រុមនេសាទសហគមន៍ចំនួន ១៨ និង ក្រុមព្រៃសហគមន៍ចំនួន ១៦ ទទួលបានការទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- អ្នកភូមិចំនួន ៨.០៤៨ នាក់ ទទួលការបណ្តុះបណ្តាលអំពីបច្ចេកទេសកសិកម្មធន់ទ្រាំអាកាសធាតុ
- មនុស្ស ៣៤.៦២៨ នាក់ពីសហគមន៍គោលដៅបានចូលរួមក្នុងសកម្មភាពលើកកំពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ

## *បណ្តាញបំពង់ទឹកផ្តល់ជូនអ្នកភូមិនូវការចាប់ផ្តើមថ្មី*

***ខេត្តកំពង់ស្ពឺ*** *- គេពុំឃើញមានសល់ដីទំនេរសោះនៅលើដីខាងក្រោយផ្ទះរបស់ គ្រី ផេន។ រងត្រកួន ស្ពៃ ផៃថាវ និងអំពៅកំពុងប្រជ្រៀតគ្នាដុះនៅលើដីទំហំ៣០០ម៉ែត្រការ៉េ តាំងពីពេលដែលគេហដ្ឋានរបស់លោក បានតភ្ជាប់បណ្តាញបំពង់ទឹក។*

*លោក គ្រី ផេន អាយុ ២៨ ឆ្នាំរស់នៅក្នុងឃុំចំបក់ ក្នុងខេត្តកំពង់ស្ពឺ បាននិយាយថា "ខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំង ចំពោះការមានកសិដ្ឋានខ្លួនឯងផ្ទាល់សម្រាប់ដាំបន្លែដើម្បីប្រកបរបរចិញ្ចឹមជីវិត"។*



*អ្នកភូមិកំពុងនាំគ្នាតបំពង់ទឹកសម្រាប់នាំទឹកស្អាតពីទឹកធ្លាក់មកប្រើប្រាស់ក្នុងគ្រួសារ ក្នុងឃុំចំបក់ ខេត្តកំពង់ស្ពឺ។*

*នៅក្នុងឃុំនេះ នៅចម្ងាយប្រមាណ ១២០ គីឡូម៉ែត្រខាងលិចរាជធានីភ្នំពេញសម័យកាលនៃកង្វះទឹកបានកន្លងផុតទៅហើយ។បណ្តាញបំពង់ទឹក"ដែលមកដល់ពេលនេះមានតែសម្រាប់អ្នកនៅក្នុងទីប្រជុំជនប៉ុណ្ណោះ"បានមកដល់លំនៅឋានជនបទរបស់គ្រួសារប្រហែល៦០០ហើយ។ដោយសារសេវាថ្មីនេះអ្នកភូមិនៅពេលនេះមិនបង្អែរបង្អង់ឡើយក្នុងការប្រែក្លាយដីក្រោយផ្ទះរបស់ខ្លួនឲ្យក្លាយទៅជាសួនបន្លែសម្រាប់បរិភោគខ្លួនឯងផង និង សម្រាប់លក់យកប្រាក់ផង ដើម្បីទ្រទ្រង់គ្រួសាររបស់ខ្លួន។*

*បណ្តាញទឹកនេះ ត្រូវបាននាំមកជូនពួកគេដោយគម្រោងមួយដែល ខិតខំជួយសហគមន៍ជនបទនៅកម្ពុជាក្នុងការបន្សាំទៅនឹងបម្រែបម្រួលអាកាសធាតុ។ គម្រោងនេះត្រូវបានឧបត្ថម្ភដោយទី ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ (SIDA) និងត្រូវបានអនុវត្តដោយកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) តាមរយៈកម្មវិធីអំណោយហិរញ្ញប្បទាន។*

*នៅក្នុងរដូវប្រាំង ទឹកស្អាតគឺជាទំនិញកម្រមួយ ហើយអ្នកភូមិបានចំណាយពេលជាមធ្យម ពីរម៉ោងក្នុងមួយថ្ងៃដើម្បីយកទឹកពីអូរឬអណ្តូងទឹកសម្រាប់ការប្រើប្រាស់។ អ្នកភូមិខ្លះត្រូវចំណាយប្រាក់ ២.៥០០ រៀល (០,៦៥ ដុល្លារអាមេរិក) សម្រាប់ទឹកមួយធុងចំណុះ ២០០ លីត្រ ដែលប្រើបានពីរបីថ្ងៃ។ តម្លៃនេះហាក់បីដូចជាមិនច្រើនទេ ប៉ុន្តែសម្រាប់ប្រជាជនក្រីក្រជនបទជាច្រើន វាគឺជាបន្ទុកដ៏ធ្ងន់មួយ។*

*បងស្រី រស់ ហេង មាតាអាយុ ២៩ ឆ្នាំដែលមានកូនចំនួនបីនាក់ និយាយថា "និយាយអំពីការលំបាកក្នុងការយកទឹកមកប្រើកាលពីមុននោះគឺវាពិបាកក្រៃលែង។ ប្តីរបស់ខ្ញុំមិនមានពេលទំនេរទេ ដោយសារគាត់ត្រូវទៅដងទឹកពីអណ្តូងទឹកសម្រាប់ ដាំស្ល ផឹក និង បោកគក់"។*

*កាលពីខែ វិច្ឆិកា ឆ្នាំទៅ ការងារបានបញ្ចប់លើបណ្តាញបំពង់ទឹកប្រវែង ២០ គីឡូម៉ែត្រមួយ ដើម្បីបង្ហូរទឹកពីជ្រោះ។ បច្ចុប្បន្ន គ្រួសារនីមួយៗនៃគ្រួសារចំនួន ៦០០ នៅក្នុងឃុំនេះបានតភ្ជាប់ទៅនឹងបណ្តាញទឹកមេនេះតាមរយៈបំពង់ទឹកតូចៗ។ ដោយកសាងលើលទ្ធផលវិជ្ជមានពីការងារ ដូចគ្នាមួយក្នុងឆ្នាំ ២០០៧ បណ្តាញទឹកថ្មីនេះ ផ្តល់ទឹកជូនអ្នកភូមិគ្រប់ពេលក្នុងមួយឆ្នាំៗសម្រាប់បង្កើនការដាំដំណាំដើម្បីកែលម្អជីវភាព និងភាពរឹងប៉ឹងរបស់ពួកគេប្រឆាំងនឹងហេតុប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ។*

*ការជួយកាត់បន្ថយការពឹងផ្អែករបស់អ្នកភូមិលើទឹកភ្លៀងសម្រាប់ការធ្វើកសិកម្ម ក៏គឺជាគោលដៅមួយផងដែរនៃបណ្តាញទឹកនេះ ដែលគឺជាសមាសភាគមួយនៃកម្មវិធីបន្សាំផ្អែកលើ សហគមន៍កម្ពុជាដែលឧបត្ថម្ភដោយអង្គការ SIDA។ ពូ ទូច ម៉ន ប្រធានសហគមន៍ទេសចរណ៍ធម្មជាតិចំបក់ បាននិយាយថាអត្ថប្រយោជន៍ដែលនាំមកដោយទឹកម៉ាស៊ីន គឺមានលក្ខណៈធំធេងច្រើនជាងការដែលគ្រាន់តែជួយឲ្យគ្រួសារអាចរកបានចំណូលបន្ថែម។ លោកបាននិយាយថាកុមារនៅពេលនេះអាចចំណាយពេលច្រើនលើការសិក្សាដោយសារពួកគេលែងចាំបាច់ខ្វល់ខ្វាយអំពីការយកទឹកឲ្យគ្រួសារពួកគេទៀតហើយ។ បណ្តាញទឹកនេះ ក៏បានជួយឲ្យអ្នក ភូមិលើកស្ទួយអនាម័យរបស់ពួកគេផងដែរ។ ចំនួនបង្គន់គ្រួសារបានកើនឡើង។ អ្នកភូមិអាចងូតទឹកញឹកញាប់ជាងមុន ចិញ្ចឹមបសុសត្វថែមទៀត និងដាំបន្លែក្នុងរដូវប្រាំងដើម្បីរកប្រាក់។*

*ពូ ទូច ម៉ន បាននិយាយថា "យើងអាចមើលឃើញការប្រែប្រួលច្រើននៅក្នុងទម្លាប់របស់ប្រជាជន។ គ្រាន់តែនៅក្នុងភូមិខ្ញុំមួយប៉ុណ្ណោះ ចំនួនបង្គន់គ្រួសារបានកើនឡើងដល់ ២០ នៅពេលនេះ ពីត្រឹមតែពីរប៉ុណ្ណោះកាលពីពេលមុន" ។*

*គ្រី ផេន បានរំលឹកថាដោយសារខ្វះទឹកក្នុងរដូវប្រាំងមុនៗ គាត់បានទុកបណ្តោយឲ្យដីនៅខាងក្រោយផ្ទះគាត់ដុះស្មៅពេញខណៈដែលគាត់បានទៅបើកត្រាក់ទ័រឲ្យអ្នកជំនួញមូលដ្ឋានម្នាក់ដើម្បីចិញ្ចឹមជីវិត។ ប៉ុន្តែ ក្រោយពេលដែលគេហដ្ឋានរបស់គាត់បានតភ្ជាប់បណ្តាញទឹកម៉ាស៊ីន គាត់បានឈប់ធ្វើការដើម្បីប្រកបអាជីវកម្មខ្លួនឯងវិញ។*

## ពង្រឹងការអភិរក្សព្រៃឈើ

គម្រោងរបស់ UNDP-មូលនិធិបរិស្ថានពិភពលោក ដែលមានតម្លៃជាទឹកប្រាក់ ៣,៨លានដុល្លា មានគោលដៅជួយកម្ពុជាថែរក្សាព្រៃឈើរបស់ខ្លួន ផ្តល់ប្រយោជន៍ដល់ជនក្រីក្រនៅជនបទ និងរួមចំណែកកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់។គម្រោងគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព កំពុងស្ថិតក្រោមការអនុវត្តពីសំណាក់រដ្ឋបាល ព្រៃឈើនៃប្រទេសកម្ពុជា។

រដ្ឋាភិបាលមានគោលដៅ បង្កើតទីតាំងសហគមន៍ព្រៃឈើទំហំពីរលានហិកតានៅទូទាំងប្រទេសរហូតដល់ឆ្នាំ ២០២៩។ បច្ចុប្បន្ននេះ មានទីតាំងសហគមន៍ព្រៃឈើចំនួន ៤៣០ ដែលគ្របដណ្តប់លើព្រៃឈើដែលមានវិសាលភាព ប្រមាណ ៤០០.០០០ហិកតា ដែលត្រូវជា ប្រមាណមួយភាគប្រាំនៃចំណុចដាំរួម។

ដើម្បីជួយទប់ស្កាត់ការរេចរឹលព្រៃឈើជាបន្ថែមទៀត គម្រោងនេះដែលនឹងបន្តអនុវត្តរហូតដល់ឆ្នាំ ២០១៥ នឹងធ្វើការបង្កើត និងគ្រប់គ្រងធុរកិច្ចដែលផ្អែកលើព្រៃឈើ នៅក្នុងសហគមន៍ព្រៃឈើប្រមាណ ៣០ និងសហគមន៍តំបន់ការពារធម្មជាតិចំនួន ១០។ អ្នកភូមិជាពិសេស ស្ត្រីនឹងរៀនផលិតចង្ក្រានដែលមានប្រសិទ្ធភាព ថាមពល ដោម្បីបង្កើនប្រាក់ចំណូល និងជួយកាត់បន្ថយតម្រូវការអុស។

ព្រៃឈើរួមចំណែកពី ៣០ ទៅ ៤០% នៃរបរចិញ្ចឹមជីវិតប្រចាំគ្រួសាររបស់ប្រជាជន ដែលរស់នៅជិតព្រៃឈើ។ ទោះវាមិនមែនជាប្រភពនៃការបំភាយឧស្ម័ន ផ្ទះកញ្ចក់ធំជាងគេក៏ដោយ កម្ពុជាងាយរងគ្រោះចំពោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ប៉ុន្តែការយល់ដឹងជាសាធារណៈអំពីបញ្ហានេះមានកម្រិតទាបណាស់។ គម្រោងនេះអះអាងអំពីកង្វល់រួមរបស់UNDPនិងការប្តេជ្ញាដើម្បីដោះស្រាយការរេចរឹលព្រៃឈើ និងកែលម្អការគ្រប់គ្រងព្រៃឈើនៅកម្ពុជាឲ្យមាននិរន្តរភាព។

នៅក្នុងពេលដែលមានកំណើនផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ មហាសន្និបាតសហប្រជាជាតិ បានប្រកាសនៅក្នុងឆ្នាំ ២០១១ ថាជាឆ្នាំអន្តរជាតិនៃព្រៃឈើ ដើម្បីបង្កើនការយល់ដឹងអំពីការគ្រប់គ្រងព្រៃឈើ។ នៅកម្ពុជា ប្រការនេះសង្កត់ធ្ងន់លើថាតើការគ្រប់គ្រង ព្រៃឈើបានសមស្របអាចរួមចំណែក បែបណាទៅក្នុងការកាត់បន្ថយភាពក្រីក្រ និងជួយរដ្ឋាភិបានសម្រេចគោលដៅចំបងមួយនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ ពោលគឺ រក្សាគម្របព្រៃឈើឲ្យនៅ ៦០% នៃផ្ទៃប្រទេស។



ទិដ្ឋភាពគម្របព្រៃនៅព្រៃសហគមន៍ក្នុងខេត្តឧត្តរមានជ័យ។

## អ្នកភូមិរីករាយដោយសារអាងទឹក ត្រូវបានស្តារឡើងវិញ



កសិករកំពុងច្រូតកាត់ស្រូវប្រាំងក្នុងឃុំទួលស្តី ដែលនៅទីនោះ ការសាងសង់ទំនប់បង្ហៀរទឹកមួយបានអនុញ្ញាតឲ្យកសិករធ្វើស្រែបានពីរដងក្នុងមួយឆ្នាំ។

**ស្វាយរៀង** - ជាលើកដំបូងក្នុងរយៈពេលជិតមួយទសវត្សរ៍ នាង តី និងអ្នកភូមិជាមួយគ្នាអាចធ្វើស្រែបានពីរដងក្នុងមួយរដូវ នៅក្នុងឃុំទួលស្តី ខេត្តស្វាយរៀង។

ការខ្វះទឹកធ្លាប់បានបង្ខំពួកគេឲ្យធ្វើដំណើរឆ្ងាយពីផ្ទះ ដើម្បីស្វែងរកការងារធ្វើ។ ប៉ុន្តែ ទំនប់បង្ហៀរមួយដែលទើបបានសាងសង់ក្នុងពេលថ្មីៗនេះ ដែលជាជញ្ជាំងបេតុងសម្រាប់គ្រប់គ្រងទឹកភ្លៀងនៅក្រោមស្ពានមួយ បច្ចុប្បន្ននេះកំពុងឆ្លើយតបទៅ នឹងការលំបាករបស់អ្នកភូមិដោយរក្សាទឹកទុកគ្រប់គ្រាន់នៅក្នុងបឹងមួយសម្រាប់ពួកគេបង្កើន ការដាំដំណាំ និងបង្កើនទិន្នផលផងដែរ។

នាងតីអាយុ៥៥ឆ្នាំបានពោលថា"ខ្ញុំនឹងត្រូវទៅសុំទានដូចមុនទៀតប្រសិនបើពុំមានទំនប់បង្ហៀរនេះទេ"។តំបន់ទំនាបធំល្វឹងល្វើយដែលអ្នកក្នុងមូលដ្ឋានស្គាល់ថាជា បឹងបាធូ គឺជាគន្លឹះនៃការរស់រាននៃសេដ្ឋកិច្ចសម្រាប់ប្រជាជន ២.៥០០នាក់ នៅក្នុងឃុំនេះ។ កាលពីមុន ជារៀងរាល់ឆ្នាំនៅក្រោយរដូវប្រមូលផលស្រូវ គឺជារដូវនៃក្តីអស់សង្ឃឹម។ ដោយសារតែកង្វះខាតទឹក អ្នកភូមិធ្វើស្រែតែមួយលើកនៅរវាងខែឧសភា និងតុលា។ បន្ទាប់មកពួកគេជាច្រើន ត្រូវតែស្វែងរកការងារធ្វើនៅកន្លែងដទៃ ដែលរួមទាំង នៅក្នុងប្រទេសវៀតណាមដែលស្ថិតនៅជិតខាងដែលពួកគេនិយាយថា នៅទីនោះជាញឹកញាប់ពួកគេច្រើនតែក្លាយជាអ្នកសូមទាននៅតាមដងផ្លូវដើម្បីរស់។

សុក សេក ប្រធានឃុំ បានពោលថា "យើងធ្លាប់ឃើញប្រជាជនចេញពីភូមិ ក្នុងចំនួនច្រើនជារៀងរាល់ឆ្នាំ ដែលធ្វើឲ្យភូមិមានសភាពស្ងាត់ជ្រងំ។ កុមារត្រូវបោះបង់ចោលសាលារៀន ដោយសារតែពួកគេត្រូវទៅជាមួយឪពុកម្តាយ"។

គាត់មានប្រសាសន៍ថា នៅទីនេះធ្លាប់មានទ្វារទឹកធ្វើពីដែកនៅត្រង់ទំនប់ពីក្រោមស្ពាននេះ ដើម្បីគ្រប់គ្រងទឹក។ ប៉ុន្តែ ដោយត្រូវច្រេះស៊ី ទ្វារទឹកនោះក៏ខូចខាតទាំងស្រុង ដោយបន្សល់ទុកនូវច្រកយ៉ាងធំមួយដែលទឹកភ្លៀងត្រូវហូរចោលទៅភាគខាងក្រោមទាំងអស់។ នៅពេលចប់រដូវប្រមូលផលស្រូវក្នុងខែធ្នូ បឹងនេះចាប់ផ្តើមរីងស្ងួតបន្តិចម្តងៗ។

គាត់ពោលថា "មិនមែនតែកសិករទេដែលប្រឈមការលំបាកនៅក្នុងរដូវប្រាំង សូម្បីតែសត្វក្របី និងគោ ក៏ពុំមានទឹកគ្រប់គ្រាន់សម្រាប់ផឹកផងដែរ"។ ស្ថានភាពចាប់ផ្តើមផ្លាស់ប្តូរហើយ នៅក្នុងខែឧសភា ឆ្នាំ ២០១១ នៅពេលដែលការកសាងសង់ទំនប់បង្ហៀរបានចប់រួចរាល់។ ជញ្ជាំងបេតុងដែលមានកំពស់ ២.២ម និងប្រវែង ៣២ម ស្ទាក់ទឹកពីការហូរចោលដោយផ្តល់ទឹកសម្រាប់ធ្វើស្រែ។

យោងតាមលោកស្រី ហេង ចាន់ថុន នាយកអង្គការវឌ្ឍនភាព ដែលជាក្រុមអង្គការមិនមែនរដ្ឋាភិបាលមួយដែលអនុវត្តការសាងសង់នៅពេលមានភ្លៀងច្រើន ទំនប់បង្ហៀរអាចរក្សាទឹកទុកសម្រាប់ស្រោចស្រពដីស្រែប្រមាណ ៨៣០ហ.ត ធៀបនឹងកាលពីមុនដែលអាចត្រឹម ២៥០ហ.ត ដែលនេះជាការកើនឡើងជាងបីដង។



ទំនប់បង្ហៀរទឹកនៅឃុំទួលស្តីត្រូវបានសាងសង់ដោយគម្រោងខ្នាតតូចរបស់ UNDP និង មូលនិធិបរិស្ថានសាកលសំដៅជួយបង្កើនជីវភាពរស់នៅរបស់អ្នកស្រុកដែលទទួលរង ផលប៉ះពាល់ពីសំណាក់ការប្រែប្រួលអាកាសធាតុ។

ការសាងសង់ទំនប់បង្ហៀរនេះ ស្ថិតក្នុងចំណោមសកម្មភាពនៅក្រោមគម្រោងចំនួន ៤៦ ដែលកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងកម្មវិធីជំនួយខ្នាតតូចនៃមូលនិធិបរិស្ថានពិភពលោក កំពុងអនុវត្តដើម្បីជួយអ្នកភូមិនៅក្នុងតំបន់ជាច្រើននៃផ្ទៃប្រទេសកម្ពុជា ក្នុងការកែលម្អការចិញ្ចឹមជីវិត ដើម្បីអាចធន់ទ្រាំនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ គម្រោងទាំងនេះទទួលមូលនិធិគាំទ្រពីរដ្ឋាភិបាលស៊ុយអែដ និងទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAid) ។ ការសាងសង់ ទំនប់បង្ហៀរនេះបានចំណាយអស់ប្រមាណ ២១.១០០ ដុល្លារអាមេរិក ក្នុងនោះ ១៩,០០០ ដុល្លារអាមេរិក ជាជំនួយឥតសំណង ពីរដ្ឋាភិបាលស៊ុយអែដ និងទឹកប្រាក់បន្ថែមចំនួន ២.០០០ ដុល្លារអាមេរិក ដែលអ្នកភូមិនៅក្នុងឃុំទួលស្តី ភាគច្រើនរស់ក្នុងផ្ទះជញ្ជាំងធ្វើពីភក់បានប្រឹងកៀរគរសម្រាប់ជាវិភាគទានដល់គម្រោងនេះ។

# ជំរុញសមភាពយេនឌ័រ

*"ដំណោះស្រាយដែលមាននិរន្តរភាព ដើម្បីពង្រឹងភាពអង់អាចខាងផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី មានសារៈសំខាន់ណាស់ក្នុងការឈានទៅមុខរបស់កម្ពុជា។ វាសំខាន់នៅក្នុងក្របខ័ណ្ឌនៃការសម្រេចបាន MDGs, និងកាន់តែសំខាន់ទៅទៀតនៅក្នុងបរិបទនៃភាពមិនប្រាកដប្រជាខាងសេដ្ឋកិច្ច"។*

*លោកជំទាវ បណ្ឌិត អ៊ុង កន្ថា ផាវី*
*រដ្ឋមន្ត្រីក្រសួងកិច្ចការនារី*

នៅពេលដែលកិច្ចប្រឹងប្រែងអភិវឌ្ឍន៍មានបញ្ចូលទាំងស្រុងនូវទស្សនវិស័យ និងការចូលរួមរបស់ស្ត្រី វានឹងបង្កឱកាសល្អបំផុតក្នុងការធ្វើឲ្យមានការរីកចម្រើនសម្រាប់ទាំងអស់គ្នា។ UNDP ធ្វើការដើម្បីពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រី ជំនាញដឹកនាំនយោបាយ និងតួនាទីធ្វើសេចក្ដីសម្រេច។

វឌ្ឍនភាពគួរឲ្យកត់សម្គាល់បានកើតមានក្នុងគោលនយោបាយ ប៉ុន្តែគម្លាតខាងយេនឌ័រនៅតែមាននៅឡើយ។ ស្ត្រីក្នុងចំនួនតិចតួចជាងបុរសស្ថិតក្នុងតំណែងធ្វើសេចក្ដីសម្រេចក្នុងវិស័យសាធារណៈ និងឯកជន និងកុមារីក្នុងចំនួនតិចតួចជាងកុមារា បន្តទៅសិក្សាជាន់ខ្ពស់។ ក្នុងកម្លាំងពលកម្មបច្ចុប្បន្ន ស្ត្រីច្រើនជាងបុរស ទំនងជាមិនចេះអក្សរ ឬមានជំនាញទាបជាងបុរស។

ក្រសួងកិច្ចការនារីខិតខំក្នុងការធានាឲ្យបានថា គោលនយោបាយនិងផែនការនានា ដែលមានការយល់ដឹងអំពីយេនឌ័រ ពិតជាត្រូវបានអនុវត្តឲ្យមានឥទ្ធិពលប្រែប្រួលប្រសើរឡើងដល់ស្ថានភាព សិទ្ធិ និងជម្រើសរបស់ស្ត្រីកម្ពុជា។ គោលបំណងជាចំបងគឺបង្កើនការចូលរួមរបស់ស្ត្រីក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ក្នុងសិទ្ធិទទួលបានការងារមានកម្រៃសមរម្យ ការបញ្ចូលសម្លេងក្នុងផែនការអភិវឌ្ឍន៍មូលដ្ឋាន និងរកកំណត់ឲ្យឃើញនូវការវិនិយោគផ្នែកថវិកាសម្រាប់ពន្លឿនការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។

UNDP គាំទ្រដល់ក្រសួងកិច្ចការនារីក្នុងការរៀបចំកិច្ចប្រជុំកំពូលថ្នាក់រដ្ឋមន្ត្រីអាស៊ីប៉ូលីស្តីពីសមភាពយេនឌ័រ ដែលមានប្រតិភូមកពី ១៦ ប្រទេសចូលរួម។ កិច្ចប្រជុំនេះធ្វើការពិនិត្យមើលការបង្កើនតួនាទីស្ត្រីក្នុងការកសាងភាពធន់ទ្រាំតល់នឹងវិបត្តិសេដ្ឋកិច្ចនិងបរិស្ថាន បង្កើនការចូលរួមរបស់ស្ត្រីក្នុងកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ ដែលពង្រឹងភាពអង់អាចរបស់ពួកគេក្នុងការប្រឈមនឹងការលំបាកតាមរយៈសេដ្ឋកិច្ចបៃតង ជីវភាពមានតុល្យភាពក្នុងការងារ និង ឱកាសសេដ្ឋកិច្ចកាន់តែប្រសើរជាងមុន។

ក្រោមការដឹកនាំរបស់ក្រសួង UNDP និង UNFPA បានគាំទ្រការសិក្សាលទ្ធភាពមួយអំពីមណ្ឌលសេវាកម្មច្រកចេញចូលតែមួយ (One-Stop Service Centre) ដើម្បីបម្រើស្ត្រីនិងប្រជាជនដែលទទួលរងអំពើហិង្សាខាងយេនឌ័រ។ វាជាការសិក្សាប៉ាន់ប្រមាណស៊ីជម្រៅមួយអំពីសេវាកម្មដែលមានស្រាប់ផ្នែកសុខាភិបាល ការប្រឹក្សាយោបល់ វិធានការទប់ស្កាត់និងការពារ និងធនធានាដែលត្រូវការចាំបាច់សម្រាប់បង្កើតមជ្ឈមណ្ឌលបែបនេះនៅកម្ពុជា។

ការលើកកំពស់ការបញ្ជ្រាបយេនឌ័រក្នុងរដ្ឋបាលសាធារណៈ ជាពិសេសនៅថ្នាក់ក្រោមជាតិ គឺស្ថិតនៅខ្ពស់ក្នុងរបៀបវារៈរបស់រដ្ឋាភិបាល។ ជាកិច្ចខិតខំយូរអង្វែងសំដៅលើកកំពស់សមភាពយេនឌ័រ រដ្ឋាភិបាលកំពុងរៀបចំ លក្ខន្តិកៈសម្រាប់ក្របខ័ណ្ឌមន្ត្រីស៊ីវិល ក្នុងគោលដៅបង្កើនអត្រាស្ត្រីនៅក្នុងក្របខ័ណ្ឌមន្ត្រីស៊ីវិល និងការធ្វើសេចក្ដីសំរេចចិត្ត។

## ស្រ្តីកម្ពុជាទទួលបានជំនាញថ្មីសម្រាប់ការរស់នៅរបស់ខ្លួន



ស្រ្តីកំពុងទទួលការបណ្តុះបណ្តាលការកាត់ដេរនៅខេត្តកំពង់ចាម តាមរយៈគម្រោងឧបត្ថម្ភដោយ UNDP សំដៅជួយពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្រ្តី។

គង់ ធារ៉ា រីករាយណាស់នៅពេលដែលនាងទទួលបានម៉ាស៊ីនដេរមួយ ដោយសារតែនាងបានពិន្ទុខ្ពស់ជាងគេនៅក្នុងវគ្គសិក្សាកាត់ដេរមួយ។ នាងនិយាយអំពីផែនការរបស់ខ្លួនក្នុងការបើកហាងកាត់ដេរមួយ និងអំពីជីវភាពប្រសើរជាងមុន ដែលនាងសង្ឃឹមថាបានមកពីមុខរបរថ្មី ដែលនាងនឹងមាននៅថ្ងៃខាងមុខ។

ក្នុងវ័យ ២២ ឆ្នាំ នាងពោលថា" ខ្ញុំមិនគិតថា ខ្ញុំនឹងនៅតែក្រទៀតទេទៅអនាគត "។

នាងជាមនុស្សម្នាក់ក្នុងចំណោម ១៧ នាក់ ដែលបានបញ្ចប់វគ្គកាត់ដេរនៅក្នុងសមាគមស្រ្តីដើម្បីសន្តិភាព និងការអភិវឌ្ឍ ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយនៅខេត្តកំពង់ចាម។

វគ្គដែលមានរយៈពេលប្រាំមួយខែនេះ គឺជាកិច្ចប្រឹងប្រែងរួមគ្នាមួយរបស់ EU និង UNDP តាមរយៈគម្រោងសហប្រតិបត្តិការអន្តរឃុំ ដែលជួយក្រុមប្រឹក្សាមូលដ្ឋានប្រមូលផ្តុំគំនិត និងមូលនិធិ ដើម្បីដោះស្រាយតម្រូវការរបស់អ្នកភូមិក្នុងមូលដ្ឋាន។ គម្រោងនេះត្រូវបានអនុវត្តនៅក្នុងខេត្តចំនួន ១២។

នៅខេត្តកំពង់ចាម មេដឹកនាំឃុំជាប់គ្នាចំនួនបួន បានឯកភាពចាត់ចែងឲ្យមានវគ្គបណ្តុះបណ្តាលមួយអំពីការកាត់ដេរ ដែលជាអាទិភាព ដើម្បីជួយស្រ្តីនៅក្នុងសហគមន៍របស់ពួកគេរកប្រាក់ចំណូល។

ដួង សុផា ប្រធានឃុំល្វៀង មានប្រសាសន៍ថា "ជំនួញកាត់ដេរត្រូវការដើមទុនតិចតួចដើម្បីចាប់ផ្តើម។ គ្រួសារក្រីក្រដែលមានម៉ាស៊ីនដេរអាចរកប្រាក់ពីការដេរអាវ ឬសំពត់។ ពួកគេពុំចាំបាច់ទៅឆ្ងាយពីផ្ទះរបស់ខ្លួនឡើយ ហើយយុវតីដែលមានការសិក្សាតិចតួចអាចរៀនសូត្រជំនាញនេះបានដោយងាយ "។

នៅក្រោមកិច្ចផ្តួចផ្តើមនេះ ឃុំទាំងបួនបានរៀបចំសំណើរួមគ្នាមួយដែលបានទទួលប្រាក់ ៥.១៨០ ដុល្លារ ពីមូលនិធិគម្រោងសហប្រតិបត្តិការអន្តរឃុំ ។ វគ្គបណ្តុះបណ្តាលនេះបានចាប់ផ្តើមនៅ ខែធ្នូ ឆ្នាំ ២០១០ ហើយនៅពេលពួកគេបញ្ចប់ការសិក្សាក្នុងខែឧសភា ឆ្នាំ ២០១១ ស្រ្តីបានទទួលម៉ាស៊ីនដេរម្នាក់មួយគ្រឿង និងឧបករណ៍ដទៃទៀតដែលចាំបាច់ ដើម្បីបង្កើតជំនួញកាត់ដេរមួយ។

សូ សាមុត ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាល បានពោលថា "សិក្ខាកាមទាំងអស់មកពីគ្រួសារក្រីក្រ។ ប្រសិនបើពួកគេមានតែជំនាញ ប៉ុន្តែគ្មានមធ្យោបាយ ពួកគេនឹងត្រូវធ្លាក់ចូលទៅក្នុងការធ្វើចំណាកស្រុកទៅធ្វើការជាកម្មករកាត់ដេរដូចពីមុន។ ប៉ុន្តែជាមួយម៉ាស៊ីនដេរ ពួកគេអាចប្រើប្រាស់សម្រាប់រកប្រាក់ដោយពុំចាំបាច់ចាកចេញពីផ្ទះឡើយ"។ សិក្ខាកាមខ្លះដែលបានបញ្ចប់ការសិក្សានេះពោលថា ពួកគេគ្រោងចូលរួមជាក្រុម ដើម្បីបង្កើតជំនួញកាត់ដេរ។

# ធ្វើការរួមគ្នា

*សកម្មភាពនានារបស់ UNDP ត្រូវបានធ្វើក្រោមកិច្ចសហការជិតស្និទ្ធជាមួយរដ្ឋាភិបាល ទីភ្នាក់ងារ អ.ស.ប និងដៃគូអភិវឌ្ឍន៍ដទៃទៀត។ ភាពជាដៃគូជាមួយសហភាពអឺរ៉ុប ស៊ុយអែដ អេស្ប៉ាញ នូវ៉ែលហ្សេឡង់ និងកាណាដា មានសារៈសំខាន់ជាស្នូលសម្រាប់សម្រេចបានលទ្ធផលនានា។*

UNDP បានបង្កើតភាពជាដៃគូជាមួយរដ្ឋសភា ក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងកិច្ចការនារី ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអប់រំ យុវជន និងកីឡា។ UNDP ធ្វើការជាមួយអភិបាលខេត្ត មន្ទីរពាក់ព័ន្ធក្រសួងនៅថ្នាក់ជាតិ។

UNDP បានធ្វើការជិតស្និទ្ធជាមួយឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ គណៈកម្មាធិការជាតិបោះឆ្នោត គណៈកម្មាធិការជាតិទន្លេមេគង្គ អាជ្ញាធរប្រេងកាតជាតិកម្ពុជា ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កសិកម្ម និងជនបទ អាជ្ញាធរសកម្មភាពមីន និងជួយជនរងគ្រោះកម្ពុជា ស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា និងគណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាច្រើនទៀត។

ក្របខ័ណ្ឌជំនួយអង្គការសហប្រជាជាតិ (UN Development Assistance Framework/ UNDAF) ត្រូវបានបន្ស៊ីជាមួយយុទ្ធសាស្រ្តចតុកោណដំណាក់កាលទីពីររបស់រដ្ឋាភិបាល និង ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ។ UNDAF មានមូលដ្ឋានលើសមិទ្ធផល និងវឌ្ឍនភាពនានាដែលសម្រេចបានក្នុងមួយទសវត្សរ៍កន្លងមកនេះ ដែលបានធ្វើឲ្យក្រុមអង្គការសហប្រជាជាតិជាដៃគូអភិវឌ្ឍន៍គួរឲ្យទុកចិត្តនិងអព្យាក្រិតមួយ។

ក្រុមអង្គការសហប្រជាជាតិប្រកាន់យកអភិក្រមសិទ្ធមនុស្ស ក្នុងការវិភាគស្ថានភាពប្រទេស និងការតស៊ូមតិដើម្បីអាទិភាពក្នុងក្របខ័ណ្ឌអភិវឌ្ឍន៍ប្រទេស។ គោលការណ៍ទាំងនេះទាមទារឲ្យមានការផ្តោតការយកចិត្តទុកដាក់លើក្រុមប្រជាជនទន់ខ្សោយ ដែលវាជាស្នូលមួយក្នុងការរៀបចំផែនការការងាររបស់ UNDAF។

នៅឆ្នាំ ២០១១, UNDP មានបុគ្គលិកជាតិ ១១៧ នាក់ និងអន្តរជាតិ ១៦នាក់។ ក្នុងចំណោមអ្នកទាំងនេះ ស្រ្តីមាន ៦២ នាក់ ធៀបនឹង ៤៦ នាក់ នៅក្នុងឆ្នាំ ២០១០។

UNDP ជួយសម្របសម្រួលការធ្វើលទ្ធកម្មទំនិញ និងសេវា ដែលមានតម្លៃសរុបប្រមាណ ៨,៤ លានដុល្លារអាមេរិក ក្នុងនោះ មានការចុះកិច្ចសន្យាជាមួយបុគ្គល និងអង្គការនានាដើម្បីផ្តល់សេវាវិជ្ជាជីវៈ និងសេវាកម្មទីប្រឹក្សាដល់ UNDP និងទីភ្នាក់ងារ អ.ស.ប ដទៃទៀត។

កម្មវិធីអ្នកស្ម័គ្រចិត្តនៃ អ.ស.ប (UNV) គឺជាអង្គភាពដែលរួមចំណែកទៅក្នុងសន្តិភាព និងការអភិវឌ្ឍតាមរយៈសកម្មភាពស្ម័គ្រចិត្តនៅទូទាំងពិភពលោក។


២២

នៅឆ្នាំ ២០១១ អ្នកស្ម័គ្រចិត្តអន្តរជាតិចំនួន ៣២ នាក់ និងជាតិចំនួន ៥ នាក់ បានបម្រើការនៅក្នុងទីភ្នាក់ងារ អ.ស.ប ចំនួន ១២ ក៏ដូចជានៅក្នុងក្រសួងនានានៃកម្ពុជាផងដែរ ដោយធ្វើការនៅក្នុងវិស័យប្រាស្រ័យទាក់ទង និងការតស៊ូមតិ ការកែលំអអភិបាលកិច្ច និងសិទ្ធិមនុស្ស យេនឌ័រ ការកាត់បន្ថយភាពក្រីក្រ សិទ្ធិមនុស្ស កិច្ចការពារជនភៀសខ្លួន សន្តិសុខស្បៀង កិច្ចគាំពារសង្គម និងគោលនយោបាយសង្គម ការប្រែប្រួលអាកាសធាតុ ប្រសិទ្ធភាពជំនួយ និងការស្ម័គ្រចិត្ត។ លើសពីនេះ ជនកម្ពុជា ៩ នាក់ បានបម្រើការជាអ្នកស្ម័គ្រចិត្ត អ.ស.ប នៅក្នុងបេសកកម្មខុសៗគ្នារបស់ អ.ស.ប នៅអាហ្វ្រិក ដែលរួមទាំងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ លីប៊ី រ៉្វាន់ដា និងស៊ូដង់ ផងដែរ។



*អ្នកស្ម័គ្រចិត្តអង្គការសហប្រជាជាតិកំពុងចូលរួមជាមួយអ្នកភូមិក្នុងការដាំកូនឈើកោងកាងនៅភូមិតំបន់ឆ្នេរមួយប៉ែកខាងត្បូងប្រទេសកម្ពុជា។*

# កិច្ចសហប្រតិបត្តិការត្បូង-ត្បូង

*ភាពជាដៃគូរបស់ UNDP ជាមួយប្រទេសនានានៅក្នុង និងក្រៅតំបន់អាស៊ី ផ្តល់ឲ្យកម្ពុជានូវឱកាសកាន់តែច្រើនជាងមុន ក្នុងការចែករំលែក និងផ្លាស់ប្តូរបទពិសោធន៍ជាមួយប្រទេសដទៃ។*

- បន្ទាប់ពីការចុះហត្ថលេខាលើអនុស្សារណៈការយោគយល់គ្នា ដែលចូលរួមជាសាក្សីដោយលោកស្រី ហេឡិន ក្លាក ប្រធាន UNDP និងលោក វេន ជាបាវ (Wen Jiabao) នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិន និងតាមរយៈកិច្ចព្រមព្រៀងភាពជាដៃគូរវាងកម្ពុជា ចិន និង UNDP, ភ្នាក់ងារកសិកម្មកម្ពុជាចំនួន ៣០ នាក់ បានធ្វើដំណើរទៅប្រទេសចិនរយៈពេលបីសប្តាហ៍ ដើម្បីសិក្សាអំពីបច្ចេកទេសដាំដំឡូងមី។ តាមរយៈការសិក្សាតាមមូលដ្ឋាន និងការបណ្តុះបណ្តាលក្នុងបន្ទប់រៀន សិក្ខាកាមពីកម្ពុជាបានឃើញការបកស្រាយបច្ចេកទេសនានា ដែលរួមទាំងការរៀបចំដី ការគ្រប់គ្រងដំណាំពីសត្វល្អិត ការប្រមូលផល និងការគ្រប់គ្រងដី និងទឹក។ សិក្ខាកាមខ្លះនឹងក្លាយជា "គ្រូបង្គោល" សម្រាប់អ្នកកសាងផែនការ និងបុគ្គលិកផ្សព្វផ្សាយអំពីការដាំដំឡូវមីផងដែរ។

- ទីភ្នាក់ងាររដ្ឋាភិបាលចំនួនបួន បានចូលរួមនៅក្នុងសិក្ខាសាលាថ្នាក់តំបន់ស្តីពីហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងប្រសិទ្ធភាពជំនួយ។ ពួកគេបានសិក្សាអំពីសារៈសំខាន់នៃការប៉ាន់ប្រមាណក្នុងក្របខ័ណ្ឌស្ថាប័នលើការចំណាយសាធារណៈសម្រាប់ការប្រែប្រួលអាកាសធាតុ និងវិធីសាស្ត្រប៉ាន់ប្រមាណរបស់ពួកគេ។ កម្ពុជាបានបង្ហាញជូនអំពីការរីកចម្រើនរបស់ខ្លួនលើហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងការសម្របសម្រួលជំនួយ។ ជាកិច្ចបន្ត បេសកកម្មមួយបានពង្រឹងការយល់ដឹងក្នុងចំណោមអ្នកពាក់ព័ន្ធនានាអំពីអភិក្រមនេះ និងជំហាននានា នៃការត្រួតពិនិត្យការចំណាយសាធារណៈ និងស្ថាប័នប្រែប្រួលអាកាសធាតុផងដែរ។ ក្របខ័ណ្ឌសម្រាប់ធ្វើការពិនិត្យនេះត្រូវបានរៀបចំឡើង និងឯកភាពពីរដ្ឋាភិបាល និងត្រូវដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំ ២០១២ ដែលនឹងនាំទៅរកការបង្កើតយន្តការហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា។

- មន្ត្រីកម្ពុជាចំនួន ២៥ នាក់ ដែលមានអ្នកកសាងគោលនយោបាយ អ្នកកសាងផែនការ និងមន្ត្រីបច្ចេកទេសមកពីមន្ទីរវិស័យនានានៃរដ្ឋាភិបាល និងអាជ្ញាធរខេត្តចំនួនពីរ បានធ្វើទស្សនកិច្ចរយៈពេលប្រាំថ្ងៃនៅប្រទេសវៀតណាមភាគខាងត្បូង ដើម្បីរៀនសូត្រអំពីទម្លាប់ល្អៗ និងមេរៀននានា អំពីប្រព័ន្ធស្រោចស្រពដែលធន់ទ្រាំនឹងអាកាសធាតុ នៅក្នុងតំបន់ទំនាបលិចទឹក បច្ចេកទេសកសិកម្មសមស្រប ការគ្រប់គ្រងធនធានទឹកឲ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធសម្រាប់កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ ការអភិរក្សដី និងប្រព័ន្ធប្រកាសអាសន្នជាមុន។ ជាកិច្ចបន្ត ក្រសួងបរិស្ថាន និងធនធានធម្មជាតិនៃប្រទេសវៀតណាម គ្រោងផ្តល់ការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសកម្ពុជាអំពីកសិកម្មដែលធន់ទ្រាំនឹងអាកាសធាតុ ការគ្រប់គ្រងធនធានទឹក និងបច្ចេកទេសដាំដំណាំ ដែលកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។

- អង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយចំនួនបានរៀនសូត្រអំពីការបង្កើតប្រព័ន្ធព័ត៌មានសហគមន៍សម្រាប់ក្រុមជនជាតិដើមមកពីប្រទេសឡាវ និងប្រទេសថៃ។

- អ្នកកសាងគោលនយោបាយ និងសមាជិកសភាមកពីប្រទេសហ្វីលីពីន និងអាហ្សង់ទីន បានមកទស្សនកិច្ចនៅកម្ពុជា ដើម្បីចែករំលែកបទពិសោធន៍នយោបាយ និងការចូលរួមរបស់ស្ត្រីនៅក្នុងនយោបាយជាមួយគណបក្សនយោបាយនានានៅកម្ពុជា អង្គការសង្គមស៊ីវិល និងក្រុមយុវជន។

- មន្ត្រីចំនួន១០រូបមកពីសម្ព័ន្ធភាពជាតិឃុំ/សង្កាត់បានធ្វើទស្សនកិច្ចនៅឥណ្ឌូនេស៊ីដើម្បីសិក្សាអំពីសមាគមរដ្ឋាភិបាលមូលដ្ឋាននៃប្រទេសឥណ្ឌូនេស៊ី។ ទស្សកិច្ចនេះបានផ្តល់ឲ្យមន្ត្រីនានានូវឱកាស ដើម្បីរៀនសូត្រអំពីការបង្កើត និងការប្រព្រឹត្តទៅនៃសមាគមរដ្ឋាភិបាលមូលដ្ឋាននៅលំដាប់ថ្នាក់ខុសៗគ្នានៃរដ្ឋាភិបាលមូលដ្ឋាន និងក្រុមប្រឹក្សានានា តួនាទី និងមុខងារគន្លឹះរបស់ពួកគេនៅក្នុងទស្សនវិស័យនៃកំណែទម្រង់វិមជ្ឈការនៅប្រទេសឥណ្ឌូនេស៊ី។ ជាកិច្ចបន្ត សម្ព័ន្ធភាពជាតិ ឃុំ/សង្កាត់ នឹងពិចារណាគំរូនៃប្រព័ន្ធនៅឥណ្ឌូនេស៊ីក្នុងការបង្កើតយុទ្ធសាស្ត្រនិរន្តរភាពហិរញ្ញវត្ថុ។ សម្ព័ន្ធភាពជាតិនេះ នឹងដើរតួនាទីមួយនៅក្នុងការសម្របសម្រួលការបង្កើតសមាគមនៃក្រុមប្រឹក្សាផ្សេងទៀតនៅថ្នាក់រាជធានី ខេត្ត ក្រុង និងស្រុកផងដែរ។
- នៅខែសីហា ឆ្នាំ ២០១១ មន្ត្រីមកពីអាជ្ញាធរប្រេងកាតជាតិកម្ពុជា (Cambodian National Petroluem Authority/CNPA) បានធ្វើទស្សនកិច្ចនៅទីម័រខាងកើត ដើម្បីសិក្សាអំពីការងារ និងបទពិសោធន៍របស់អាជ្ញាធរប្រេងកាតទីម័រខាងកើត ក៏ដូចជាបទពិសោធន៍របស់ប្រទេសនេះក្នុងការគ្រប់គ្រងកិច្ចសន្យាប្រេងកាត និងផលចំណូលពីប្រេងកាតផងដែរ។ ទាំងមន្ត្រីទីម័រខាងកើត និងមន្ត្រីកម្ពុជា វាយតម្លៃខ្ពស់ចំពោះឱកាសក្នុងការចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងវិស័យប្រេងកាត និងឧស្ម័ន។ ដំណើរទស្សនកិច្ចនេះបានធ្វើឡើងសំដៅជួយ CNPA លើការកសាងគោលនយោបាយរបស់ខ្លួន។
- មន្ត្រីបួនរូបមកពីអគ្គនាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានធ្វើដំណើរទៅប្រទេសឡាវកាលពីខែ វិច្ឆិកា ឆ្នាំ ២០១១ ដើម្បីសិក្សាអំពីការគ្រប់គ្រងធនធានរ៉ែ។ មន្ត្រីទាំងនេះបានធ្វើទស្សនកិច្ចនៅការិយាល័យរដ្ឋាភិបាល និងបានផ្លាស់ប្តូរបទពិសោធន៍ជាមួយមន្ត្រីឡាវ អំពីគោលនយោបាយរ៉ែ និងការគ្រប់គ្រងផលចំណូល។ ពួកគេក៏បានធ្វើទស្សនកិច្ចនៅតាមទីតាំងអណ្តូងរ៉ែសំខាន់ៗខ្លះៗផងដែរ ដើម្បីស្វែងយល់ឲ្យបានច្បាស់ជាងមុនអំពីការប្រឈមសំខាន់ៗ ក៏ដូចជា អំពីស្តង់ដារនៃការអនុវត្តល្អៗ/ស្តង់ដារអន្តរជាតិ ក្នុងការគ្រប់គ្រងសកម្មភាពអាជីវកម្មរ៉ែ និងការអភិវឌ្ឍសហគមន៍ដោយក្រុមហ៊ុនរ៉ែផងដែរ។
- សមិទ្ធផលរបស់កម្ពុជាក្នុងការដោះមីនស្ថិតក្នុងចំណោមការគូសបញ្ជាក់សំខាន់ៗនៅក្នុងកិច្ចប្រជុំលើកទី១១ នៃបណ្តារដ្ឋភាគីក្នុងអនុសញ្ញាហាមឃាត់គ្រាប់មីនប្រឆាំងមនុស្ស ដែលកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ កាលពីខែវិច្ឆិកាកន្លងទៅ។ កម្ពុជាបានឆ្លៀតឱកាសនេះ ដើម្បីបង្ហាញជូនអំពីការរីកចម្រើន និងការប្រឈមរបស់ខ្លួនដល់ប្រទេសដទៃទៀតដែលរងគ្រោះដោយសារគ្រាប់មីន និងដើម្បីធ្វើការអំពាវនាវឡើងវិញដល់សហគមន៍អន្តរជាតិឲ្យបន្តរក្សាការគាំទ្រដល់សកម្មភាពបោសសំអាតគ្រាប់មីននៅទូទាំងពិភពលោក។ កម្ពុជាបានចែករំលែកជំនាញបច្ចេកទេសរបស់ខ្លួនជាមួយបណ្តារដ្ឋរងគ្រោះដទៃទៀត តាមរយៈសិក្ខាសាលាមួយស្តីពីការរំដោះដីធ្លី ដែលបានចាត់ចែងឡើងនៅសៀមរាបកាលពីខែកញ្ញា ដែលក្នុងនោះមានប្រទេសច្រើនជាងដប់បានចូលរួម និងតាមរយៈការធ្វើទស្សនកិច្ចរបស់មន្ត្រីពីប្រទេសនេប៉ាល់ ប៉េរូ និងថៃ។

# ចំណាយរបស់កម្មវិធី

| ការគាំទ្រពីដៃគូអភិវឌ្ឍន៍ ចំនួនទឹកប្រាក់ជាដុល្លារអាមេរិក | |
|---|---|
| UNDP ( មូលនិធិស្នូល ) | ៥.៤៨៤.២២៥ |
| SIDA ( ស៊ុយអែដ ) | ៤.០២៦.០០៩ |
| AusAID ( អូស្ត្រាលី ) | ២.៦៨៥.៣៩៦ |
| EU ( សហភាពអឺរ៉ុប ) | ២.១៨៤.៣៤៦ |
| CIDA ( កាណាដា ) ដែលរួមទាំង DFAIT | ២.០០៤.១៤០ |
| GEF ( កាណាដា ) ដែលរួមទាំង DFAIT | ១.៥៨៤.១៣៤ |
| DANIDA | ៥៦៤.៥៦៥ |
| នូវ៉ែលហ្សេឡង់ | ៤៦០.៨៨២ |
| អេស្ប៉ាញ | ៣០៥.៣១៥ |
| DGTTF | ២៥០.០០០ |
| ន័រវេស និងណ្វ៉ាដ | ២១៦.៧១៨ |
| DFID | ១៥០.៥៧៧ |
| UN-REDD | ៦២.៦០៧ |
| UNDP 11888 | ៣៤.០៥២ |
| អុកស្វាមអាមេរិក | ២៧.៦៣៤ |
| UNFPA | ២១.៤០០ |
| មជ្ឈមណ្ឌលតំបន់នៃ TTF HIV/AIDS | ១១.២៥៣ |
| បារាំង | ១០.៨៨៧ |
| មូលនិធិសមធម៌យេនឌ័រ ( តំបន់ ) | ៩.៦២៧ |
| UNAIDS | ២.០០០ |
| អៀរឡង់ | ១២០ |
| **សរុប ( លានដុល្លារអាមេរិក )** | **២០.០៩៦.៨៨៨** |

Design by Graphic Roots: www.graphicroots.net

UNDP

*Empowered lives.*
*Resilient nations.*

**United Nations Development Programme**

Pasteur Street, Boeung Keng Kang
P. O. Box 877, Phnom Penh, Cambodia
Tel : (855) 23 216 167 or 214 371
Fax : (855) 23 216 257 or 721 042
E-mail : registry.kh@undp.org
http: //www.undp.org